# ឯកសារស្រាវជ្រាវ

# RESEARCH PAPERS

N°=1

2015




**Seminar of Research on**

**KEYS VALUES TO BUILD CAMBODIAN SOCIETY IN THE XXI^st^ CENTURY**

# មាតិកា Content

- កាលវិភាគ Schedule

- ការបើកសិក្ខាសាលា៖ **គុណតម្លៃសម្រាប់ការកសាងសង្គមកម្ពុជាក្នុងសតវត្សទី២១**

CONFERENCE INAUGURALE : **Valeurs pour construire le CAMBODGE du XXIème siècle (**Mgr Olivier Schmitthaeusler)

I. **ឯកសារស្រាវជ្រាវ Research Documents**

១ សេចក្តីថ្លៃថ្នូររបស់មនុស្ស និងផលប្រយោជន៍រួម ( សាស្ត្រាចារ្យ Stefania-Gandolfi ប៊ឺហ្គាម៉ូ ប្រទេសអ៊ីតាលី )

Human Dignity and Common Good

Prof. Stephania Gandolfo Bergamo/Italy ....................................................១១-២៧

២ បញ្ហាប្រឈមសម្រាប់យុវជនដើម្បីកសាងសង្គមកម្ពុជាក្នុងបរិបទអាស៊ាន

សាស្ត្រាចារ្យ ង៉ែត សុខា ប្រធានដេប៉ាតឺម៉ង់សង្គមកិច្ចនៃវិទ្យាស្ថានសន្តប៉ូល

Challenges for Cambodia's youth to build the society in

the ASEAN context by professor Ngeth Sokha....................................**២៨-៣៩**

៣ ព្រះពុទ្ធសាសនា៖ គុណតម្លៃសម្រាប់សង្គមកម្ពុជានៅក្នុងសតវត្សទី ២១ ដើម្បីកសាង

វិបុលភាពក្នុងភាពចុះសម្រុងគ្នា និងសន្តិភាព (ព្រះតេជគុណ គូ សុភាព សាស្ត្រាចារ្យ

ទស្សនវិជ្ជានៃព្រះពុទ្ធសាសនា សាកលវិទ្យាល័យបញ្ញាសាស្ត្រភ្នំពេញ)

KEYS VALUES TO BUILD CAMBODIAN SOCIETY IN THE 21st CENTURY ........... ៤០-៤២

៤ អ៊ីស្លាមសាសនា៖គុណតម្លៃសម្រាប់កសាងវិបុលភាពក្នុងភាពចុះសម្រុងគ្នា

និងសន្តិភាពនៅកម្ពុជាក្នុងសតវត្សទី២១(ឯកឧត្តម អ៊ូងជី លីសាវី

ជាអ៊ីម៉ាំ ប្រចាំខេត្តកំពត)

Islam ៖ Some keys Values for the Cambodian Society

in this 21th Century to Build prosperity in harmony and peace?.................៤៣-៤៥

៥ គ្រីស្តសាសនា៖ គុណតម្លៃសម្រាប់សង្គមកម្ពុជានៅក្នុងសតវត្សទី២១ដើម្បីកសាង
វិបុលភាពក្នុងភាពចុះសម្រុងគ្នានិង សន្តិភាព លោកអភិបាល អូលីវីយេ មីផែលម៉ារីជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជានាយកនៃវិទ្យាស្ថានសន្តប៉ូល
The Catholic religion: Valuable dignity for Cambodia society in the 21rt
century in order to build prosperity, reconciliation and peace........................៤៦-៥៦

៦ ទស្សនវិស័យ និងផែនការសកម្មភាពដើម្បីក្លាយជាតួអង្គអភិវឌ្ឍន៍នៃសង្គមកម្ពុជា
(លោក សន ជ័យ ប្រធានបណ្តាញគណនេយ្យភាពសង្គម)
Perspectives and Action Plan to Social development Actor in Cambodia
by SAN Chey, ANSA-EAP Perspectives and Action Plan to Social
development Actor in Cambodia....................................................................៥៧-៦០

II. **សិក្ខាសាលាដើម្បីសំយោគសិក្ខាសាលា និងពិភាក្សាក្រុម-Workshops** .....................៦១-៦៣

III. **សរុបសេចក្តី Final Statement** .......................................................... ៦៤-៦៧

IV. **ពិធីបិទសិក្ខាសាលា Conclusion Remarks**......................................................៦៨-៧២

**កាលវិភាគ Schedule**

# សិក្ខាសាលា ស្តីពី
# គុណតម្លៃសម្រាប់ការកសាងសង្គមកម្ពុជាក្នុងសតវត្សទី២១
# នៅវិទ្យាស្ថានសន្តប៉ូល ខេត្តតាកែវ ថ្ងៃទី១៨-២០ ខែឧសភា ឆ្នាំ២០១៥

**Seminar of Research on**

**Saint Paul Institute, Takeo, 18-20 May 2015**

| ម៉ោង/Time | សកម្មភាព/ប្រធានបទ/Event | អ្នកទទួលខុសត្រូវ/PR |
|---|---|---|
| ថ្ងៃទី១៖ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥/DAY1: MONDAY 18TH MAY 2015 | | |
| 8:00-8:25 | ការចុះឈ្មោះ Registration | បុគ្គលិកSPI/ SPI Staff |
| 8:25-8:45 | អញ្ជើញមកដល់នៃភ្ញៀវកិត្តិយស<br>Arrival of Guests of Honor | បុគ្គលិកSPI/ SPI Staff |
| 8:45-9:30 | ការបើកសិក្ខាសាលា៖ **គុណតម្លៃសម្រាប់ការកសាងសង្គមកម្ពុជាក្នុងសតវត្សទី២១**<br>Inaugural Conference | លោកអភិបាលអូលីវីយេស្មីតហស្លេរ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ & នាយកវិទ្យាស្ថានសន្តប៉ូល<br>Bishop Olivier Schmitthaeusler, Bishop of Vicar Apostolic of Phnom Penh, Rector of the Saint Paul |
| 9:30-10:00 | សម្រាក និងអាហារសម្រន់/Coffee Break | បុគ្គលិកSPI/ SPI Staff |
| 10:10-11:00 | សេចក្តីថ្លៃថ្នូររបស់មនុស្ស និងផលប្រយោជន៍រួម<br>Human Dignity and Common Good<br>Prof. Stephania Gandolfo Bergamo/Italy | លោកស្រីសាស្ត្រាចារ្យ Stephania Gandolfi ( Bergamo ប្រទេសអ៊ីតាលី<br>Prof. Stephania Gandolfi Bergamo/Italy ) |
| 12:15-14:00 | សំរាក និងអាហារថ្ងៃត្រង់<br>Lunch Pause | |

| | | |
|---|---|---|
| 14:00-15:00 | បញ្ហាប្រឈមសម្រាប់យុវជនដើម្បីកសាងសង្គមកម្ពុជានៅក្នុងបរិបទអាស៊ាន<br>សាស្ត្រាចារ្យ ង៉ែត សុខា<br>Challenges for Cambodia's youth to build the society in the ASEAN context<br>By professor Ngeth Sokha | សាស្ត្រចារ្យង៉ែត សុខា ជាប្រធាន ដេប៉ាតឺម៉ង់សង្គមកិច្ច នៃវិទ្យាស្ថានសន្តប៉ូល)<br>Prof. Ngeth Sokha from Saint Paul Institute with team of Students Social Work Department, |
| 15:00-16:00 | សិក្ខាសាលា (១)/ Workshop 1 | |
| 16:30-17:30 | ការពិភាក្សាតុមូល (១)/ Round Table 1 Debate | |
| ថ្ងៃទី២៖ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥/ Day2 TUESDAY 19 MAY | | |
| 8:00-9:00 | ព្រះពុទ្ធសាសនា៖ គុណតម្លៃសម្រាប់សង្គមកម្ពុជានៅក្នុងសតវត្សទី២១ ដើម្បីកសាងវិបុលភាព ក្នុងភាពចុះសម្រុងគ្នា និងសន្តិភាព<br>Buddhism: Some keys Values for the Cambodian Society in this 21th Century to build prosperity in harmony and peace?<br>ព្រះតេជគុណ គូ សុភាព | ព្រះតេជគុណ គូ សុភាព សាស្ត្រចារ្យទស្សនៈវិជ្ជានៃព្រះពុទ្ធសាសនា សកលវិទ្យាល័យបញ្ញាសាស្ត្រ ភ្នំពេញ<br>Vernaable Kou Sopheap National Buddhist University |
| 9:00-10:00 | ឥស្លាមសាសនា៖ គុណតម្លៃសម្រាប់សង្គមកម្ពុជានៅក្នុងសតវត្សទី២១ ដើម្បីកសាងវិបុលភាព ក្នុងភាពចុះសម្រុងគ្នា និងសន្តិភាព<br>Islam: Some keys values for the Cambodian Society in this 21th Century to build prosperity in harmony and peace?<br>ឯ. អ៊ូងជី លីសារី | ឯកឧត្តម អ៊ូងជី លីសារ អ៊ីមាំប្រចាំខេត្តកំពត<br>His Excellency Imam of Kampot Province |
| 10:00-10:30 | សម្រាក និងអាហារសម្រន់/Coffee Break | បុគ្គលិកSPI/ SPI Staff |

| | | |
|---|---|---|
| 10:30-11:30 | គ្រិស្តសាសនា៖ គុណតម្លៃសម្រាប់សង្គមកម្ពុជានៅក្នុងសតវត្សទី២១ ដើម្បីកសាងវិបុលភាពក្នុងភាពចុះសម្រុងគ្នា និងសន្តិភាព<br>Christianity: Some keys Values for the Cambodian Society in this 21th Century to build prosperity in harmony and peace ? | លោកអភិបាល អូលីវីយេ នាយកវិទ្យាស្ថានសន្តប៉ូល<br>His Excellency Bishop Olivier Schmitthaeusler |
| 12:00-14:00 | សម្រាក និងអាហារថ្ងៃត្រង់<br>Lunch-Pause | |
| 14:00-16:00 | សិក្ខាសាលា ( ២ )/ Workshop2 | |
| 16:30-17:30 | ការពិភាក្សាតុមូល ( ១ ) Round Table2 Debate | |
| ថ្ងៃទី៣៖ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥/ DAY3: WEDNESDAY 20 MAY 2015 | | |
| 9:00-10:00 | ទស្សនវិស័យ និងផែនការសកម្មភាពដើម្បីក្លាយជាតួអង្គ អភិវឌ្ឍន៍ នៃសង្គមកម្ពុជា<br>Vision and Action Plan to be effective actor of the development of the Cambodian Society | Youth Committee for Unity and Development ( to confirmed ) |
| 10:0010:30 | សម្រាក និងអាហារសម្រន់/ Coffee Break | បុគ្គលិកSPI |
| 10:30-12:00 | សិក្ខាសាលា( ៣ )/ Workshop3<br>៦ក្រុមដើម្បីសំយោគសិក្ខាសាលា និងការពិភាក្សា<br>6 groups to synthesize conference and debate | សាស្រ្តាចារ្យង៉ែត សុខា និងនិស្សិតដេប៉ាតឺម៉ង់សង្គមកិច្ច |
| 12:15-14:00 | សំរាក និងអាហារថ្ងៃត្រង់/ Lunch Pause | |
| 14.00-15.00 | សំនួរ / ចម្លើយ- Questions/Answer | Prof.Sokha Ngeth from Saint Paul Institute with team of Students Social Works Department |
| 15:00-15:30 | សម្រាក និងអាហារសម្រន់/Coffee Break | បុគ្គលិកSPI/ SPI Staff |
| 15:30-17:00 | ការបិទវគ្គសិក្ខាសាលា /Closing Remarks<br>ការប្រគល់វិញ្ញាបនបត្រ និងការថតរូបជុំគ្នា<br>Giving Certificate and Group Photo | Mgr Olivier Schmitthaeusler |
| 17:30 | អាហារពេលល្ងាច/ Dinner | |

# មតិស្វាគមន៍របស់នាយកវិទ្យាស្ថាន
## ថ្ងៃច័ន្ទ ១៨ ឧសភា ២០១៥ នៅវេលាម៉ោង ០៨:៤៥
## "តម្លៃដ៏ថ្លៃថ្នូរជាគ្រឹះ ដើម្បីសាងសង់ព្រះរាជាណាចក្រកម្ពុជា នាសតវត្សទី ២១"
## គ្រឹះស្ថានសន្តៈប៉ូល ក្រុងតាកែវ ព្រះរាជាណាចក្រកម្ពុជា
## ១៨-២០ ឧសភា ២០១៥
### ដោយ លោកអភិបាល អូលីវីយេ ឝ្មិតហះស្លេរ
## CONFERENCE INAUGURALE
## Valeurs pour construire le CAMBODGE du XXIème siècle
### Mgr Olivier Schmitthaeusler

សូមគោរពលោកស្រីសាស្ត្រាចារ្យ Gandolfi ជាទីគោរព

សូមគោរពលោក លោកស្រីជាសាស្ត្រាចារ្យ ជាទីគោរព

សូមគោរពអស់លោកគង្វាលនិងបព្វជិត បព្វជិតាទាំងឡាយ ជាទីស្រឡាញ់

សូមគោរពអស់លោកនាយកវិទ្យាល័យ

សូមគោរពអស់និស្សិតនៃវិទ្យាស្ថានសន្តៈប៉ូល ជាទីស្រឡាញ់

សូមគោរពអស់មិត្តអ្នកដែលអញ្ជើញចូលរួម ក្នុងសិក្ខាសាលាស្វែងរករបស់យើង។

ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត និងមានអំណរជាអតិបរិមានឹងបើកសិក្ខាសាលាស្វែងរករបស់យើងនេះ ដែលមានប្រធានបទ "តម្លៃដ៏ថ្លៃថ្នូរ ជាគ្រឹះដើម្បីសាងសង់ព្រះរាជាណាចក្រកម្ពុជានៅសតវត្សទី ២១"។

គ្រឹះស្ថានសន្តៈប៉ូលចាត់ចែងសិក្ខាសាលាបែបនេះជាលោកទី ២ ហើយ។

ខ្ញុំសូមអរគុណសាកលវិទ្យាល័យក្រុង Bergamo និងអាសនៈអង្គការ Unesco សម្រាប់សិទ្ធិមនុស្ស និងសមាគម Vittorino Chizzolini ដែលបានជួយឲ្យសិក្ខាសាលានេះអាចចាប់បដិសន្ធិឡើងបាន។

បីឆ្នាំកន្លងមក ខ្ញុំបានជួបអ្នកស្រី Stefania Gandolfi ។ ការជួបនោះជាមូលហេតុ ដែលយើងអាចជួបជុំគ្នាបាននៅថ្ងៃនេះ។ សូមអរគុណអ្នកស្រីសាស្ត្រាចារ្យជាពន្លឺកដែល អ្នកស្រីអញ្ជើញចូលរួមជាមួយយើងក្នុងសិក្ខាសាលាស្វែករក និងរិះគិតអស់រយៈពេលបីថ្ងៃខាងមុខនេះ។នៅឆ្នាំនេះ យើងបានលើកយកប្រធានបទបន្តពីការរិះគិតនៃសិក្ខាសាលានៅឆ្នាំកន្លងមក ដែលមានប្រធានបទ "ការចងចាំនិងអត្តសញ្ញាណ"។

នៅឆ្នាំនេះយើងត្រូវរិះគិតអំពីអ្វីដែលជាតម្លៃសំខាន់ដ៏ថ្លៃថ្នូរ ជាគ្រឹះដែលយើងត្រូវការ ជាចាំបាច់ និងដែលខានមិនបានដើម្បីសាងសង់សង្គមនៅព្រះរាជាណាចក្រកម្ពុជាយើងឲ្យបានសុខដុមរមនានិងបានប្រកបដោយសន្តិភាព។ យើងត្រូវរិះគិតដូច្នេះដើម្បីសាងសង់សង្គមនៅព្រះរាជាណាចក្រកម្ពុជាយើង ក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចដ៏ជឿនលឿននាសព្វថ្ងៃជាពិសេស ដោយគិតគូរដល់ទីផ្សារសេរីនៃសមាគមអាស៊ាន

ដែលត្រូវបើកជាផ្លូវការនៅចុងឆ្នាំ ២០១៥ ខាងមុខនេះ។ យើងក៏ត្រូវបញ្ជូនបន្តតម្លៃសំខាន់ដ៏ថ្លៃថ្នូទាំងនោះដល់កូនចៅនិងដល់យុវជនយុវនារីតៗទៅ។

នៅថ្ងៃដើមដំបូងនេះ យើងនឹងពិនិត្យមើលសង្គមយើងនាបច្ចុប្បន្នកាល។ អ្នកស្រីសាស្ត្រាចារ្យ Gandolfi នឹងជួយចាក់គ្រឹះជាមូលដ្ឋាននៃសិក្ខាសាលានេះ ដោយថ្លែងសេចក្តីស្តីអំពីកិត្តិយសរបស់មនុស្ស និងអំពីប្រយោជន៍រួម។ បន្ទាប់មក អ្នកស្រី Anne Lemaistre ជានាយិកានៃអង្គការ Unesco នៅភ្នំពេញ នឹងថ្លែងអំពីឧបសគ្គនិងអត្ថប្រយោជន៍ដែលព្រះរាជាណាចក្រកម្ពុជាយើង ត្រូវប្រឈមមុខក្នុងបរិបទសមាគមអាស៊ាន។ នៅទីបញ្ចប់ លោកសាស្ត្រាចារ្យ ង៉ែត សុខា និងនិស្សិតខ្លះៗ ដែលរៀនផ្នែកសង្គមវិជ្ជានៅវិទ្យាស្ថានសន្តៈប៉ូល នឹងផ្តល់យោបល់អំពីឧបសគ្គនានា និងអត្ថប្រយោជន៍ដែលព្រះរាជាណាចក្រកម្ពុជាត្រូវប្រឈមមុខក្នុងសង្គមបច្ចុប្បន្ន។

នៅថ្ងៃទីពីរ យើងនឹងរិះគិតតាមសាសនាដ៏សំខាន់ៗ ដែលមាននៅព្រះរាជាណាចក្រកម្ពុជាយើងគឺព្រះតេជគុណ គូ សុភាព ដែលបង្រៀននៅសាកលវិទ្យាល័យបញ្ញាសាស្ត្រមានពុទ្ធដិកាអំពីព្រះពុទ្ធសាសនា។ លោកអ៊ីម៉ាមនៃខេត្តកំពតនឹងមានប្រសាសន៍អំពីអ៊ីស្លាមសាសនា។ លោកឯកឧត្តម លី សារី និងខ្ញុំផ្ទាល់នឹងនិយាយអំពីគ្រីស្តសាសនា។ អស់លោកនឹងជួយឲ្យយើងរិះគិតតាមលទ្ធិសាសនានីមួយៗ អំពីតម្លៃដ៏ថ្លៃថ្នូរជាគ្រឹះដើម្បីឲ្យប្រទេសយើងអាចអភិវឌ្ឍដោយសុខដុមរមនាបាន។ នៅថ្ងៃបង្ហើយ យើងនឹងស្តាប់ សម្លេងនៃសង្គមស៊ីវិលតាមរយៈអង្គការក្រៅរដ្ឋាភិបាល គឺអង្គការ COMFREL ដែលរៀបរាប់អំពីការបោះឆ្នោតសេរី។ រីឯអង្គការ ANSA នឹងចែកយោបល់អំពីការប្រព្រឹត្តតាមរបៀបដែលនាំឲ្យប្រជាពលរដ្ឋអាចដឹងឮនូវអ្វីៗដែល រាជរដ្ឋាភិបាលសម្រេច។ យោបល់ទាំងនោះមុខជាផ្តល់ឱកាសបើកផ្លូវខ្លះៗ សម្រាប់ជួយឲ្យយើងរិះរកសេចក្តីពិត។ ហេតុទាំងនេះហើយទើបយើងទាំងអស់គ្នាអាចទៅជាអ្នកដែលយកចិត្តទុកដាក់យ៉ាងស្វាហាប់ដើម្បីសាងសង់ប្រទេសយើងដោយយកយុត្តិធម៌ និងការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់ៗធ្វើជាមូលដ្ឋានគ្រឹះ។

នៅពេលរសៀលជារៀងរាល់ថ្ងៃយើងនឹងបែកចេញជាក្រុមរិះគិតទាំងអស់៦ក្រុមដើម្បីឲ្យម្នាក់ៗមានលទ្ធភាពអាចរួមចំណែកយ៉ាងសកម្មក្នុងការិះគិតនោះ គឺម្នាក់ៗអាចផ្តល់យោបល់បាន។ រួចយើងនឹងជួបជុំគ្នាជាអង្គប្រជុំរួមទូទៅ។

អស់លោក លោកស្រីជាទីគោរព !

យើងត្រូវចាប់អារម្មណ៍នឹងប្រធានបទដែលយើងបានជ្រើសរើសនេះជាបន្ទាន់ ដោយនឹកគិតដល់ការបើកទីផ្សាររួមក្នុងសមាគមអាស៊ាននៅថ្ងៃទី ៣១ ធ្នូខាងមុខនេះ។ រដ្ឋាភិបាលនៃប្រទេសទាំងដប់នៃសមាគមអាស៊ាន តែងតែជួបជុំគ្នាជាញឹកញាប់ នាយករដ្ឋាភិបាលនៃប្រជាជាតិនានា ក៏តែងជួបជុំគ្នាតាមកម្រិតខ្ពស់ដែរ ដើម្បីរៀបចំការព្រមព្រៀងខាងនយោបាយ និងខាងសេដ្ឋកិច្ច ក្នុងគោលបំណងបើកទីផ្សារការងារ និង

សម្រួលការចេញចូលនៃទំនិញក្នុងសមាគមអាស៊ាននេះ។ ចុះការកសាងប្រជាជននានា ដើម្បីឲ្យមនុស្សម្នាក់ៗអាចទទួលអ្នកដទៃបាន ទាំងគោរពសេចក្តីប្លែកៗពីគ្នា និងគោរពកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតរបស់មនុស្សទៅជាយ៉ាងណា ?

ប្រទេសនានានៃសហភាពអឺរ៉ុប រស់នៅជាមួយគ្នាជាង ៦០ ឆ្នាំមកហើយតែត្រូវប្រឈមមុខនឹងវិបត្តិក្នុងសង្គម។ មានប្រទេសជាច្រើនចង់វិលត្រឡប់ទៅរកប្រយោជន៍របស់ខ្លួនវិញ។ ពេលសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ជាអភិបាលនៃព្រះសហគមន៍សកលធ្វើទស្សនកិច្ចទៅរដ្ឋសភាអឺរ៉ុប នាថ្ងៃ ២៥ វិច្ឆិកាកន្លងមកលោកដាស់តឿនសហភាពអឺរ៉ុបឲ្យស្ទុះឡើង សូមយកបុគ្គលមកដាក់នៅចំកន្លែងសំខាន់ជាងគេក្នុងការសម្រេចនានារបស់អស់លោក។ លោកបានត្រាស់ហៅយ៉ាងខ្លាំងឲ្យសហភាពអឺរ៉ុបគោរព កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតរបស់មនុស្ស (រដ្ឋសភាអឺរ៉ុបនៅក្រុងស្រ្តាស្បួរ ថ្ងៃ ២៥ វិច្ឆិកា ២០១៤)។ តើយើងមានដែលភ្ញាក់ស្មារតីថាប្រសិនបើគ្មានដាក់មនុស្សនិងដាក់ការអភិវឌ្ឍទាំងស្រុងរបស់បុគ្គលទៅជាគោលដ៏សំខាន់ជាងគេគ្រប់ផែនការខាងសេដ្ឋកិច្ចនិងខាងនយោបាយទាំងប៉ុន្មានទោះបីគេបានរៀបចំនិងរិះគិតយ៉ាងជ្រៅយ៉ាងណាក៏ដោយក៏ត្រូវរលំជាមិនខានឬទេ? នេះជាការប្រឈមមុខដ៏ធំ។ គ្រប់សាកលវិទ្យាល័យ និងអស់អ្នកស្វែងរកទាំងសង្គមស៊ីវិលទាំងអង្គការការពារសិទ្ធិមនុស្ស ហើយជាពិសេសសាសនាដ៏សំខាន់ៗនៅសមាគមអាស៊ានត្រូវខិតខំរិះគិតជាបន្ទាន់ គឺត្រូវកសាងចិត្តគំនិតមនុស្សទាំងអស់ ដោយចង់គោរពសិទ្ធិជាគ្រឹះរបស់មនុស្ស។

គួរឲ្យស្តាយណាស់ រដ្ឋាភិបាលប្រទេសយើងទាំងអស់គ្នា ក៏នៅតែជាប់ប្រទ្បាក់នឹងអំពើពុករលួយសកម្មជាប់នឹងការប្រកាន់ក្រុមគ្រួសារ។ រដ្ឋការទាំងប៉ុន្មាន មានរឿងបែបទាំងនោះជារៀងរាល់ថ្ងៃ។ ព្រឹត្តិការណ៍នានាដែលកើតឡើងនាឆ្នាំកន្លងមកនេះក៏បានបង្ហាញបញ្ហាផ្សេងៗឲ្យគេដឹងគ្រប់គ្នា គឺជាបញ្ហាដែលនៅតែកើតឡើងឥតឈប់ឈរ។ យើងសូមរំឭកអំពីបញ្ហាដ៏ធ្ងន់ធ្ងរជាងគេ ( សូមអានសេចក្តីរាយការណ៍ខាងសេដ្ឋកិច្ច និងខាងនយោបាយរបស់លោកភិបាលអូលីវីយេ ឆ្មឹតហស្លែរ ទៅក្រុមអភិបាលព្រះសហគមន៍កម្ពុជា-ឡាវ ២០១៥)។

* ជម្លោះអំពីដីធ្លី ការបណ្តេញអ្នកតូចតាចជាងគេដោយអយុត្តិធម៌ ដើម្បីឲ្យក្រុមហ៊ុនអនាមិក រឹបអូសយកដីដែលមានជីវជាតិល្អជាងគេដោយរកតែប្រយោជន៍របស់ខ្លួនផ្ទាល់។
* មានរោងចក្រពាសពេញប្រទេសយើងមានកម្មករកម្មការិនីរាប់សែននាក់ ។តែថៅកែតែងតែរំលោភសិទ្ធិជាគ្រឹះនៃការងារ និងមិនសូវអនុវត្តតាមការណែនាំអំពីសុវត្ថិភាពនិងអនាម័យផង។
* ព្រៃព្រឹក្សាដ៏ល្អប្រណិតរបស់យើង ដែលមានដើមឈើដ៏មានតម្លៃខ្ពស់ តែងតែបាត់បង់ទៅដោយគ្មាននរណាអាចឃាត់បាន ដើម្បីជាប្រយោជន៍ដល់មនុស្សតែមួយក្រុមតូច។
* មានកម្មកររាប់សែននាក់ចេញទៅរកការងារនៅប្រទេសអាស៊ានផ្សេងៗ ហើយក៏ត្រូវរងគ្រោះជាញឹកញាប់ទាំងធ្លាក់ខ្លួនទៅជាទាសករទំនើប ដូចសម្តេចប៉ាប្រហ្វង់ស៊ីស្កូជាអភិបាលនៃព្រះសហគមន៍

សកលហៅទាសភាពបែបនេះ (សារស្ដីអំពីសន្តិភាព នៅថ្ងៃទី ១ មករា ឆ្នាំ ២០១៥)។

*មានកាស៊ីណូកើតកាន់តែច្រើនឡើងនៅតាមព្រំដែន ដែលបណ្ដាលឲ្យអស់លោកអ្នកដែលញៀន នឹងការល្បែងស៊ីសងបំផ្លាញជីវិតមនុស្សនិងក្រុមគ្រួសារជាច្រើន ហើយជាពិសេសធ្វើឲ្យអ្នកខ្លះបាន ចំណេញយ៉ាងអស្ចារ្យ។ អ្នកបានចំណេញទាំងនោះ ក៏ជាក្រុមតែមួយតូចដដែលនោះដែរ។

* មានធ្វើជំនួញមនុស្សគ្រប់ប្រភេទ ដែលប៉ះពាល់ភូមិដាច់ស្រយាល ដើម្បីលក់ដូរទាំងសរីរាង្គទាំង រូបកាយរបស់មនុស្សគ្មានទោស។

ប្រជាពលរដ្ឋជាច្រើននាក់ក្នុងប្រទេសយើង ក៏តែងជួបប្រទះគ្រោះកាចបែបនេះក្នុងការរស់នៅប្រចាំ ថ្ងៃរបស់គេដែរ។ នេះជាមុខដ៏លាក់កំបាំងនៃការអភិវឌ្ឍន៍។ ប៉ុន្តែយើងមានអំណរដោយឃើញថា ប្រទេស យើងអភិវឌ្ឍយ៉ាងពិតប្រាកដ និងចម្រើនឡើងរហូតដល់ ៧,៤ ក្នុងឆ្នាំ ២០១៤ នេះ។ ក្នុងឋានៈយើងជាអ្នក ទទួលខុសត្រូវលើការសិក្សានៅគ្រប់កម្រិតតាំងពីសាលាមត្តេយ្យរហូតដល់សាកលវិទ្យាល័យក្នុងឋានៈយើង ជានាយកអង្គការសិទ្ធិមនុស្ស អង្គការសម្រាប់ជួយយុវជនយុវនារី និងអង្គការអភិវឌ្ឍប្រទេសយើង ក្នុងឋានៈ យើងជាអ្នកទទួលខុសត្រូវខាងសាសនា មានពុទ្ធសាសនា អ៊ីស្លាមសាសនា និងគ្រីស្តសាសនា យើងក៏ត្រូវ ទទួលចំណែកយ៉ាងសកម្មក្នុងការសាងសង់សមាគមអាស៊ានដែរ។

គ្រីស្តទូតយ៉ូហានប្រៀនប្រដៅយើងយ៉ាងខ្លាំងៗថា ៖"យើងមិនត្រូវស្រឡាញ់ត្រឹមតែបបូរមាត់ ឬពាក្យ សម្ដីប៉ុណ្ណោះទេតែត្រូវស្រឡាញ់តាមអំពើដែលយើងប្រព្រឹត្ត និងតាមសេចក្ដីពិតវិញ" (១យហ ៣: ១៨)

យើងត្រូវតែយកចិត្តទុកដាក់រិះគិតអំពីបញ្ហាទាំងនេះជាបន្ទាន់ ដោយនឹកគិតចង់យកបុគ្គល និង កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតរបស់មនុស្ស មកដាក់នៅចំកណ្ដាលនៃការអភិវឌ្ឍន៍ គឺ ៖

- ត្រូវអប់រំយុវជនយុវនារីអំពីការប្រឈមមុខនៃអាស៊ាន
- ត្រូវខិតខំឲ្យយល់អំពីបញ្ហាសង្គមរបស់យើងដែលកំពុងតែអភិវឌ្ឍ
- ត្រូវប្រឈមមុខ ដើម្បីជាប្រយោជន៍ដល់ក្រុមគ្រួសារ យុវជនយុវនារី កម្មករ ជនអន្តោប្រវេសន៍
- ត្រូវទទួលអ្នកដទៃ និងត្រូវសម្រុះសម្រួលប្រជាជននានា ដែលជួនការបានទាស់ទែងគ្នាយ៉ាង សាហាវកាលពីអតីតកាលមក។

សូមឲ្យសិក្ខាសាលាយើងនេះ ទៅជាឱកាសរិះគិតអំពីវិភាគទានរបស់យើងក្នុងការសាងសង់ប្រទេស យើងដោយសំអាងលើតម្លៃដ៏ថ្លៃថ្នូរខ្លះជាគ្រឹះ គឺយុត្តិធម៌សេចក្ដីពិតនិងសេចក្ដីស្រឡាញ់។ មនុស្សគ្រប់រូប ស្វះស្វែងចង់រស់នៅក្នុងសន្តិភាពនិងសុខដុមរមនា។ យើងត្រូវយកសន្តិភាពនិងសេចក្ដីសុខដុមរមនានោះ មកដាក់នៅចំកណ្ដាលនៃទីផ្សាររបស់សមាគមអាស៊ាន។ តើនរណានឹងដាក់សន្តិភាពនិងសេចក្ដីសុខ ដុមរមនានោះបានដូច្នេះ ? យើងសង្ឃឹមថាសិក្ខាសាលានេះទៅជាឱកាសឲ្យយើងជួយយកវិភាគទានរបស់

យើង ផ្ទាល់ដល់ការកសាងសមាគមអាស៊ាន ដូចជាយកដុំថ្មតូចមួយក្នុងការកសាងវិមានរួមដ៏ធំដូច្នោះដែរ។ សូមឲ្យសិក្ខាសាលានេះ លើកទឹកចិត្តទាំងគ្រូបង្រៀន ទាំងនិស្សិតយើងឲ្យសម្លឹងមើលអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមតាមរបៀបថ្មីផង។

ក្នុងសារលិខិតក្រោមចំណងជើងថាការចម្រើននៃប្រជាជននានាសម្តេចប៉ាបប៉ូលទី ៦បញ្ជាក់ថា មិនគ្រាន់តែបុគ្គលប៉ុណ្ណោះទេ តែប្រជាជាតិនានាដែរត្រូវជួបជុំគ្នាដោយមានមតិប្រកបដោយភាតរភាព។ លោកពន្យល់ទៀតថា៖"យើងត្រូវរួមសហការគ្នាដើម្បីកសាងអនាគតរួមនៃមនុស្សជាតិដោយស្តាប់គ្នា និងដោយស្រឡាញ់គ្នាទៅវិញទៅមកដែលជាការរួបរួមដ៏សក្ការៈ"។ ជាអាទិ៍ភារកិច្ចនេះជាភារកិច្ចរបស់អ្នកមានច្រើនជាងគេ។ ភារកិច្ចរបស់គេចាក់ឫសក្នុងភាតរភាពរបស់មនុស្ស និងក្នុងសាសនានានាហើយមានចំណុចបីយ៉ាង (ហ្វ្រង់ស៊ីស្កូជាអភិបាលព្រះសហគមន៍សកលទិវាសន្តិភាព ឆ្នាំ ២០១៤) គឺ ៖

- ភារកិច្ចនៃការរួមសាមគ្គី ដែលទាមទារឲ្យប្រជាជាតិដែលមានច្រើនជាងគេ ជួយប្រទេសដែលអន់។
- ភារកិច្ចនៃយុត្តិធម៌ក្នុងសង្គម ដែលទាមទារឲ្យតែងតាំងទំនាក់ទំនងរវាងប្រទេសដែលមានកម្លាំង និងប្រទេសទន់ខ្សោយ តាមរបៀបថ្មីប្រកបដោយយុត្តិធម៌ ។
- ភារកិច្ចនៃសេចក្តីស្រឡាញ់សាកលទូទៅ ដែលទាមទារការតែងតាំងមនុស្សលោកដែលមានលក្ខណៈជាមនុស្សសម្រាប់បុគ្គលទាំងអស់ គឺក្នុងពិភពលោកនោះបុគ្គលម្នាក់ៗឬប្រទេសនីមួយៗត្រូវមានអ្វី ចែកចាយដល់គេ និងទទួលពីគេបានដែរ។ ក្នុងពិភពលោកថ្មីនោះ មិនត្រូវឲ្យការចម្រើនរបស់ក្រុមណាមួយ ទៅជាឧបសគ្គរាំងការអភិវឌ្ឍន៍ក្រុមឯទៀតៗជាដាច់ខាត។

ក្នុងសិក្ខាសាលាអស់រយៈពេលបីថ្ងៃខាងមុខនេះ យើងនឹងរិះគិតអំពីភាតរភាព និងអំពីការស្វែងរកសេចក្តីពិត។ យើងនឹងខិតខំស្វែងរកគោលការណ៍ដ៏សំខាន់ខ្លះដើម្បីជៀសវាងមិនឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយគ្មានការអភិវឌ្ឍន៍ខាងផ្លូវចិត្តគំនិតមនុស្ស និងបើកចិត្តគំនិតគេឲ្យចេះទទួលអ្នកដទៃដែលប្លែកពីខ្លួនទាំងគោរពសិទ្ធិមនុស្ស ជាគ្រឹះរបស់បុគ្គលម្នាក់ៗ។

ខ្ញុំអធិដ្ឋានសូមឲ្យការរិះគិតរបស់យើងទទួលបានលទ្ធផលល្អតាមបំណង។

ខ្ញុំសូមប្រកាសថា សិក្ខាសាលាស្រាវជ្រាវស្តីអំពី គុណតម្លៃដើម្បីកសាងសង្គមកម្ពុជានៅសតវត្សទី២១ នាឆ្នាំ ២០១៥ បើកហើយ។ សូមអរគុណ។

**មតិស្វាគមន៍របស់នាយកវិទ្យាស្ថាន**
**ថ្ងៃច័ន្ទ ១៨ ឧសភា ២០១៥ នៅវេលាម៉ោង ០៨:៤៥**
**"តម្លៃដ៏ថ្លៃថ្នូរជាគ្រឹះ ដើម្បីសាងសង់ព្រះរាជាណាចក្រកម្ពុជា នាសតវត្សទី ២១"**
**គ្រឹះស្ថានសន្តៈប៉ូល ក្រុងតាកែវ ព្រះរាជាណាចក្រកម្ពុជា**
**១៨-២០ ឧសភា ២០១៥**
**ដោយ លោកអភិបាល អូលីវីយេ ឝ្មិតហស្លែរ**

**CONFERENCE INAUGURALE**
**LUNDI 18 mai 2015 – 8.45**
**Valeurs pour construire le CAMBODGE du XXIème siècle**
**INSTITUT CATHOLIQUE SAINT PAUL – TAKEO - CAMBODGE**
**Mgr Olivier Schmitthaeusler**

Madame le Professeur Gandolfi
Mesdames et Messieurs les Professeurs,
Chers Pères et Chères Sœurs,
Messieurs les directeurs de Lycée,
Chers Etudiants de l'Institut Saint Paul,
Chers amis venus se joindre à notre séminaire de recherche,

C'est un honneur et une grande joie pour moi d'ouvrir ce séminaire de recherche sur le thème Valeurs pour construire le CAMBODGE du XXIème siècle
C'est la deuxième fois que l'Institut Saint Paul organise un tel séminaire.
Je remercie l'université de Bergame, la Chaire de l'Unesco pour les Droits de l'Homme et l'Association Vittorino Chizzolini qui ont permis à ce séminaire de voir le jour.
C'est grâce à une rencontre il y a quatre ans avec Madame Stefania Gandolfi, que nous sommes ici aujourd'hui. Immense merci à vous chère Madame le Professeur d'être parmi nous pour ces trois jours de recherche et de réflexions.
Le thème retenu pour cette année est dans la continuité de ce que nous avions mené comme réflexion lors du séminaire de recherche de l'an passé : Mémoire et Identité.

Cette année, il s'agira de réfléchir aux valeurs essentielles et indispensables que nous devons transmettre aux jeunes générations afin de construire la société cam–

bodgienne en harmonie et en paix dans un contexte de développement économique rapide en particulier à l'horizon du marché commun de l'Asean qui s'ouvrira officiellement à la fin de l'année 2015.

Cette première journée sera consacrée à porter un regard sur notre société actuelle.

Madame le Professeur Gandolfi nous aidera à poser les bases de notre séminaire avec un conférence sur la dignité humaine et le bien commun. Madame Anne Lemaistre, Directrice de l'Unesco à Phnom Penh évoquera les défis auxquels le Cambodge doit faire face dans le contexte de l'Asean. Enfin M. le Professeur Ngeth Sokha avec quelques étudiants du département de sociologie de Saint Paul, nous donnera son point de vue quant aux défis que les jeunes en particulier, rencontrent dans la société actuelle.

La seconde journée sera réservée aux principales religions présentes au Cambodge : Le bouddhisme, avec le Vénérable Kou Sopheap de l'Université de Panahsa, l'Islam avec l'Imam de la Province de Kampot, son Excellence Ly Sary et le Christianisme avec moi-même pour nous aider à réfléchir à l'enseignement de chacune de ces religions au regard de valeurs fondamentales pour que notre pays puisse se développer harmonieusement.

Le dernier jour, nous donnerons la voix à la société civile à travers deux organisations non-gouvernementales, COMFREL pour des élections libres et ANSA pour la transparence. Ce sera l'occasion d'ouvrir quelques pistes dans notre recherche de la vérité pour qu'ensemble nous devenions des acteurs passionnés pour construire notre pays sur des valeurs de justice et de respect des droits de chacun.

Chaque après-midi, nous aurons 6 groupes de travail afin que chacun puisse participer activement à la réflexion en donnant son opinion avant de nous retrouver en assemblée plénière pour un débat.

## Mesdames et Messieurs,

Le thème choisi est urgent à prendre en compte avec l'ouverture imminente du marché commun de l'Asean le 31 décembre 2015.

Si les gouvernements des dix pays de l'ASEAN, aux fils des sommets et de multiples

réunions, préparent des accords politiques et économiques pour ouvrir le marché du travail et faciliter les importations et exportations de marchandises, qu'en est-il de la construction des peuples pour que chacun puisse accepter l'autre dans sa différence et respecter la dignité transcendante de l´Homme?

L'Europe, après plus de 60 ans de "vie commune", est confrontée à des crises sociétales de replis identitaires. Lors de sa visite au parlement Européen, le 25 novembre dernier, le Pape François a appelé l'Europe à un sursaut pour mettre la personne humaine au centre des ses décisions et a lancé un appel urgent au respect de la dignité transcendante de l'homme. (Parlement Européen, Strasbourg, 25 novembre 2014)

Sommes-nous conscients que tous les plans économiques et politiques aussi élaborés soient-ils s'écrouleront, si l'homme et son développement intégral ne sont pas la clé de voûte du système ?

Voilà un grand défi me semble-t-il auquel les universités et leurs chercheurs, la société civile et ses ongs de défense des droits de l´homme et en particulier les grandes religions des pays de l´Asean devrait s'atteler : construire les cœurs et les esprits dans le respect des droits fondamentaux de l'homme.

Nos gouvernements sont encore malheureusement entachés par la corruption active, le népotisme. « Les affaires » sont le pain quotidien de nos administrations.

L´actualité de cette année passée a une fois de plus mis au grand jour des problèmes récurrents. Pour ne citer que les plus criants (cf. Mgr olivier SCHMITTHAEUSLER, Rapport économie et politique – Cambodge – Celac 2015) :

- les conflits fonciers, avec les expulsions injustes des plus petits pour que de grands conglomérats obscurs récupèrent les meilleures terres pour leurs profits propres ;
- les usines tapissent nos pays avec des centaines de milliers d'ouvriers dont les droits fondamentaux du travail, le respect des règles de sécurité et d'hygiène sont tant malmenés ;
- nos belles forêts riches d'essence précieuses disparaissent sous nos yeux impuissants, pour là encore, le profit de quelques uns ;
- des centaines de milliers d'ouvriers partent vers d'autres pays de l'ASEAN et

sont bien souvent victimes de ce que le Pape François appelle l'esclavage moderne (Message pour la Paix, 1er Janvier 2015) ;

- les casinos fleurissent à nos frontières pour assouvir l'addiction destructrice de tant de vies et de familles, de malheureux joueurs, mais surtout pour faire les bénéfices énormes de quelques uns (toujours les mêmes d'ailleurs) ;
- les trafics humains en tout genre touchent les villages les plus retirés pour acheter organes et corps innocents.

C'est la réalité quotidienne de beaucoup de nos concitoyens. C'est la face cachée du développement effectif et réel dont nous sommes les heureux témoins avec près de 7,5% cette année 2014 encore.

En tant que responsable de l´enseignement à tous les niveaux depuis l´école maternelle jusqu'à l´université, en tant que directeurs d´ONG pour les droits de l´homme, la jeunesse et le développement du pays, en tant que responsables religieux, bouddhistes, musulmans et chrétiens, nous devons prendre notre part active à la construction de l´Asean.

L'apôtre Jean nous dit avec vigueur : "N'aimons pas en paroles ni par des discours, mais par des actes et en vérité." (1 Jn 3,18).

La formation des jeunes générations aux enjeux de l´Asean, la compréhension des problèmes de nos sociétés en développement, les défis pour la famille, les jeunes, les travailleurs, les pauvres, les migrants, l'ouverture à l'accueil des autres et à la réconciliation entre les peuples, qui parfois ont un lourd passé historique, sont des questions que nous devons prendre en compte de façon urgente en replaçant au centre la personne humaine et sa dignité transcendante.

Que ce séminaire soit une occasion pour  réfléchir à notre contribution pour construire notre pays sur des valeurs fondamentales de justice, de vérité et de charité.

La paix et l'harmonie qui sont au centre des aspirations de tout Homme, doivent être mis au coeur de ce marché économique commun. Mais qui les mettra ?

Espérons que ces trois jours seront une occasion d´apporter notre pierre à cet édifice commun et stimuler nos enseignants et nos étudiants à porter un regard nouveau sur le vrai développement économique et social.

Le pape Paul VI affirmait dans sa lettre encyclique Populorum progressio (26 mars

1967), que non seulement les personnes mais aussi les nations doivent se rencontrer dans un esprit de fraternité. Et il explique : « Dans cette compréhension et cette amitié mutuelles, dans cette communion sacrée, nous devons [...] œuvrer ensemble pour édifier l'avenir commun de l'humanité ».

Ce devoir concerne en premier lieu les plus favorisés. Leurs obligations sont enracinées dans la fraternité humaine et surnaturelle et se présentent sous un triple aspect : (Pape François, Journée pour la Paix 2014)

- le devoir de solidarité, qui exige que les nations riches aident celles qui sont moins avancées ;
- le devoir de justice sociale qui demande la recomposition en termes plus corrects des relations défectueuses entre peuples forts et peuples faibles ;
- le devoir de charité universelle, qui implique la promotion d'un monde plus humain pour tous, un monde dans lequel tous aient quelque chose à donner et à recevoir, sans que le progrès des uns constitue un obstacle au développement des autres.

Notre travail pour ces trois jours sera, dans la fraternité et la recherche de la vérité, d'essayer de donner quelques repères essentiels pour que le développement économique ne se fasse pas sans un développement des esprits et des coeurs et une ouverture à l'autre dans sa différence dans le respect des droits fondamentaux de chacun.

Je souhaite que nos travaux soient fructueux.

Je déclare le séminaire de recherche 2015 ouvert.

Merci pour votre attention

# I- ឯកសារស្រាវជ្រាវ Research Documents

## ១ សេចក្ដីថ្លៃថ្នូររបស់មនុស្ស និង សមិទ្ធិ កម្មទ្រព្យសម្បត្តិរួម

**Dignité de la personne et réalisation du bien commun"**

**Prof. Stephania Gandolfo Bergamo/Italy**

សិទ្ធិដែលគ្មានភាពថ្លៃថ្នូរ គឺគ្រាន់តែជាភាពអប្បបញ្ញាហើយភាពថ្លៃថ្នូរដែលគ្មាន គឺគ្រាន់តែជាការខ្វះវិចារណញ្ញាណ (ប្លែសប៉ាស្កាល់,ភាពបណ្ដុំនៃគំនិត)។តាមទស្សនវិទូប៉ូលរីកឺរ (Paul Ricoeur) គោលគំនិតនៃសេចក្ដីថ្លៃថ្នូរសំដៅចំពោះគំនិតដែលថាអ្វីៗគឺ បណ្ដាលមកពីមនុស្សដោយហេតុតែវាមានសភាវៈជាមនុស្ស។ តាមការពិតឫសគល់នៃពាក្យ Dignitas សំដៅទៅលើអ្វីដែលថ្លៃថ្នូរ គុណធម៌ កិត្តិយស ការពិចារណា ការរាប់អាន ហើយជួនកាលពាក្យ dignitas ធ្វើឲ្យយើងគិតដល់ការគោរពដែលមនុស្សម្នាក់សមនឹងទទួលបាន និងជួនកាលសំដៅទៅលើការគោរពចំពោះខ្លួនឯងវិញ។

សេចក្ដីថ្លៃថ្នូរមិនមែនជាឧត្តមគតិ និងមិនមែនជាវត្ថុបំណង។ វាជាគោលការណ៍ដែលដឹកនាំជីវិតមនុស្សម្នាក់ៗ ហើយក្នុងនាមជាគោលការណ៍ ភាពថ្លៃថ្នូរមិនអាចដូរទិញបាន ពីព្រោះវាពិចារណាទៅលើបុគ្គលណាម្នាក់ក្នុងភាពខុសប្លែកពីគេ នៅក្នុងសមត្ថភាពតាំងចិត្ត និងយោងទៅនឹងអ្នកដទៃផងដែរ។ វាជាគោលការណ៍ដែលតាមរយៈនោះ បុគ្គលម្នាក់មិនដែលអាចត្រូវចាត់ទុកថាជាវត្ថុមួយ ឬជាមធ្យោបាយមួយឡើយ ប៉ុន្តែវាជាគោលដៅមួយ និងជាអង្គភាពសង្ឃន្និកៈមួយ។អ្វីដែលអាចធ្វើឲ្យអ្វីមួយក្លាយជាវត្ថុដែលវិសេសជាងគេបំផុត មិនមានតម្លៃ មិនដាច់ខាតប៉ុណ្ណោះទេ ពោលគឺជាតម្លៃមួយ ប៉ុន្តែវាជាគុណសម្បត្តិសង្ឃន្និកៈមួយដែរ ពោលគឺជាសេចក្ដីថ្លៃថ្នូរមួយ ។ មនុស្សជាតិក៏ជាសេចក្ដីថ្លៃថ្នូរមួយដែរ៖ មនុស្សមិនអាចត្រូវចាត់ទុកថាជាមធ្យោបាយសាមញ្ញមួយទេ ប៉ុន្តែត្រូវចាត់ទុកជាគោលដៅមួយជានិច្ច៖ គឺគោលដៅនេះហើយដែលផ្ទុកនូវភាពថ្លៃថ្នូររបស់មនុស្ស។

ជាតុពិតទៅ ភាពថ្លៃថ្នូរគឺជាគុណសម្បត្តិមួយ ពីព្រោះវាអះអាងពីមនុស្ស អះអាងពីធនធាន និងគុណសម្បត្តិ សង្ឃន្និកៈ និងដូច្នេះគឺជាកម្លាំងនៃគំនិតដែលធ្វើឲ្យមនុស្សក្លាយជាគុណសម្បត្តិមួយដែលត្រូវគោរព និងជាគុណសម្បត្តិឯកឯងមួយដែលត្រូវការការពារ។ សម្រាប់ប៉ាស្កាល់សេចក្ដីថ្លៃថ្នូរស្ថិតនៅក្នុងគំនិត "មនុស្សគ្រាន់ជាដើមត្រែងមួយដើមប៉ុណ្ណោះ ជារុក្ខជាតិដែលខ្សោយជាងគេនៃធម្មជាតិ ប៉ុន្តែជាដើមត្រែងដែលគិតពិចារណា។ សេចក្ដីថ្លៃថ្នូររបស់មនុស្សទាំងអស់ស្ថិតនៅក្នុងគំនិត។ នៅចំណុចនេះហើយ

ដែលយើងត្រូវលើកឡើង គឺមិនមែនលម្អ ឬរយៈពេលដែលយើងនឹងអាចបំពេញនោះទេ។ ដូច្នេះយើងត្រូវខំប្រឹងគិតពិចារណាឲ្យបានល្អ៖ នេះហើយជាគោលការសីលធម៌។ ដើម្បីឲ្យស្ថិតស្ថេរនៅក្នុងពិភពមួយដែលរាល់ទំនាក់ទំនងទាំងអស់ចូលទៅក្នុង "ប្រព័ន្ធទំនិញ" ក្នុងពិភពដែលអ្វីៗអាចទិញនិងលក់បាន នោះសេចក្តីថ្លៃថ្នូររបស់មនុស្សគឺស្ថិតនៅក្នុង "លំដាប់ដែលគ្មានតម្លៃ"។

គោលគំនិតនៃសេចក្តីថ្លៃថ្នូរទាក់ទងទៅនឹងគោលគំនិតការគោរព និងការប្រមាថដែលទាមទារការទទួលស្គាល់ដែលគោរពខ្លួនឯង និងគោរពអ្នកដទៃ។ វាទទួលឥទ្ធិពលពីចំណង់នៃភាពអាចគោរពបាននិង បង្ហាញពីមនោសញ្ចេតនាដែលបុគ្គលមានដោយផ្តើមចេញពីគុណសម្បត្តិផ្ទាល់របស់ខ្លួន។ ការគោរពផ្តោតទៅលើការការពារទិដ្ឋភាពចំណុះគ្នា និងច្រើនប្រការរបស់មនុស្សចាប់តាំងពីបូរណភាពខ្លួនប្រាណរហូតដល់បូរណភាពចរិយា និងវឌ្ឍនភាពបុគ្គល ជាគោលគឺការគោរពដោយឥតលក្ខខ័ណ្ឌ មិនពាក់ព័ន្ធ នឹងអាយុ ភេទ ស្ថានភាពសុខភាពរាងកាយ និងផ្លូវចិត្ត លក្ខខ័ណ្ឌសង្គម សាសនា និងសាវតាជាតិឡើយ ។

សេចក្តីថ្លៃថ្នូរមានការទទួលស្គាល់ផ្នែកនយោបាយរបស់ខ្លួន និងគតិយុត្តិនៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សជាសាកលឆ្នាំ១៩៤៨ ដែលទទួលស្គាល់ថា មនុស្សគ្រប់រូបមាន "សេចក្តីថ្លៃថ្នូរដែលជាប់នឹងខ្លួន"(បុព្វកថា)។ នៅក្នុងបុព្វកថាគេចែងថា សេចក្តីថ្លៃថ្នូរជា "មូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅក្នុងពិភពលោក" ហើយគេបានបញ្ជាក់ពីភាពជាសាកលរបស់វាដែលស្តែងឡើងនៅក្នុងយុគភាពនៃសិទ្ធិ ហើយសិទ្ធិទាំងនេះក៏បើកទស្សនវិស័យមួយចំពោះសមិទ្ធិកម្មនៃសហគមន៍ និងសង្គមទាំងអស់ ។

មាត្រាមួយនៃសេចក្តីប្រកាសបានចែងថា៖ មនុស្សទាំងអស់កើតមកមានសេរីភាព និងស្មើភាពគ្នាទាំងលើសេចក្តីថ្លៃថ្នូរនិងសិទ្ធិ។ ពួកគេមានហេតុផល និងសម្បជញ្ញៈ និងត្រូវធ្វើទង្វើផ្សេងៗចំពោះគ្នាទៅវិញទៅមកនៅក្នុងស្មារតីភាតរភាព"។ មាត្រានេះទទួលស្គាល់ពី "លក្ខខណ្ឌរបស់មនុស្សរវាងទង្វើ និងកាតព្វកិច្ច និងភារកិច្ចគ្មានអវសាននៃសិទ្ធិមនុស្ស និងភាពមិនដាច់ខាតនៃទិដ្ឋន័យ និងភាពដាច់ខាតនៃការទាមទាររហូតដល់ភាតរភាព ដែលចូលមិនដល់"។ ហេតុដូចនេះ សេចក្តីថ្លៃថ្នូរគេមិនអាចកែប្រែបានទេ ហើយអំណាចសាធារណៈនីមួយៗត្រូវគោរពសេចក្តីថ្លៃថ្នូរនោះ ពីព្រោះវាជាកត្តារួមរបស់បុគ្គលម្នាក់ៗ និងគូសបង្ហាញពីលក្ខន្តិកៈថ្មីមួយរបស់សេចក្តីថ្លៃថ្នូរនោះ"។

សេចក្តីថ្លៃថ្នូរគឺជាការប្រឆាំងដែលបុគ្គលម្នាក់ធ្វើចំពោះអ្វីដែលបដិសេធវា។ ការប្រឆាំងនេះសមាមាត្រទៅនឹងកម្រិតនៃការប្រមាថមើលងាយនិងការគំរាមដែលវាយប្រហារទៅលើវា៖កាលណាមនុស្សជាតិកាន់តែមានការប្រមាថធ្ងន់ធ្ងរ សេចក្តីថ្លៃថ្នូរកាន់តែលេចឡើងជាកម្លាំងនៃការតស៊ូដែរ។ គេត្រូវតែតស៊ូជានិច្ចដើម្បីចេញពីស្ថានភាពនានាដែលប្រមាថដល់ សេចក្តីថ្លៃថ្នូរតាមរយៈសមត្ថភាពនៃការតូចចិត្តពីព្រោះការតូចចិត្តគឺជាទិដ្ឋភាពមួយទៀតនៃសេចក្តីថ្លៃថ្នូរនិងការគោរព ដែលយើងម្នាក់ៗត្រូវផ្តល់ឲ្យវានៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ។ វាក៏ជាកត្តាសំខាន់ដែលត្រូវអះអាងថា ការស្អប់រួមនឹងគត្តិសព្ទ បង្កើតទៅជាធនធានមួយសម្រាប់ជីវិតនៅក្នុងសង្គម នៅពេលដែលការត្រួតពិនិត្យសម្បជញ្ញៈឯកត្តបុគ្គល និងស្ថាប័នសាធារណៈក្លាយទៅជាទន់ខ្សោយ ។ ប៉ុន្តែសេចក្តីថ្លៃថ្នូរគឺជាកម្មសិទ្ធិរបស់មនុស្សទាំងអស់ ដែលយល់ព្រមទទួលស្គាល់សេចក្តីថ្លៃថ្នូរ ហើយការទទួលស្គាល់នេះ មានន័យថាជឿជាក់ទៅលើមនុស្សជាតិ និងចាត់ទុកថាដូចជាកន្លែងមួយដែលបានរស់នៅដោយអ្នកដទៃម្នាក់ ឬទាំងអស់គ្នា។ មុខរបស់អ្នកដទៃនាំឲ្យខ្ញុំសម្លឹងមើលផុតពីខ្លួនខ្ញុំផ្ទាល់។ នេះជាការអំពាវនាវដែលជាសក្ខីភាពនៃភាពផុយស្រួយរបស់អ្នកដទៃ និងដែលកោះហៅទំនួលខុសត្រូវរបស់ខ្ញុំចំពោះគេ។ តាមការពិត "សេចក្តីថ្លៃថ្នូរ ជាការឆ្លុះបញ្ចាំងពីការជឿជាក់លើខ្លួនឯង ដែលអាចមើលឃើញនៅក្នុងទឹកមុខរបស់អ្នកដទៃ៖ វាជាគុណសម្បត្តិ រូបភាពរបស់ខ្លួនឯង និងសន្ទស្សន៍នៃផលប្រយោជន៍ដែលមនុស្សម្នាក់ៗសំដៅទៅដល់ នៅក្នុងការប្រឈមមុខទៅនឹងតម្លៃធំជាងគេ ទៅនឹងរូបផ្តល់រង្វាន់ ទៅនឹងតម្រុយផលប្រយោជន៍ដែលសង្គមបញ្ជូនឲ្យ នៅពេលដែលសង្គមក្តោបក្តាប់មនុស្ស"។

មានសេចក្តីថ្លៃថ្នូរបីកម្រិតដែលឆ្លាស់គ្នា៖ សេចក្តីថ្លៃថ្នូរប្រាណវិជ្ជា ដែលពាក់ព័ន្ធនៃភាពនៅរួមជាមួយនិងលំដាប់មនុស្ស សេចក្តីថ្លៃថ្នូរអត្តវិស័យដែលគេយល់និងបែបបាតុភូតវិទ្យា និងចុងក្រោយសេចក្តីថ្លៃថ្នូរវត្ថុវិស័យ ដែលអភិវឌ្ឍឡើងនៅក្នុងបទពិសោធន៍ដែលបានឆ្លងកាត់ និងដែលចង្អុលបង្ហាញពីទស្សនវិស័យសីលធម៌"។

នៅទីនេះខ្ញុំកំណត់ត្រឹមសេចក្តីថ្លៃថ្នូរប្រាណវិទ្យាដែល ជាមូលដ្ឋានសំខាន់នៃជីវិតរបស់មនុស្សម្នាក់ៗនៃយើង ជាទ្រព្យដែលចែករំលែកដោយគ្រប់គ្រួសារមនុស្ស ជាទ្រព្យបុគ្គល។ វាមិនមែនជាទំនិញមួយទេ ប៉ុន្តែជា មុខមួយហើយក្នុងឋានៈបែបនោះ វាក៏ជាទ្រព្យសមូហភាពមួយដែរ។ យោងទៅតាម ឡឺវីណាស៍ គឺជាមុខមួយ ដែលក្លាយទៅជានាមអសាធារណ៍របស់មនុស្ស។ ជាសភាវៈមួយដែលអភិសមាចារញ៉ាំងឲ្យយើងទៅរកហើយដែលញ៉ាំងយើងឲ្យធ្វើការសង្កេតនៅក្នុងលក្ខខណ្ឌជាក់ស្តែង ដើម្បីមើលឃើញថាតើសេចក្តីថ្លៃថ្នូរអ្វីដែលយើងគ្រោងទុកឲ្យវា ប្រសិនបើវាគ្មានទីជម្រក ប្រសិនបើវាផុយស្រួយប្រសិនបើវារស់នៅក្រោមសហគមន៍ និងប្រឈមមុខនឹងការបាត់បង់អត្ថន័យនៃជីវិតរបស់វា។ឥរិយាបថសីលធម៌ត្រូវតែញុះយើង

នៅពេលយើង នៅចំពោះស្ថានភាព នៅពេលដែលវានៅចំពោះមុខយើង នៅក្នុងសង្កាត់យើងមានជនក្រីក្រដែលជាសាក្សី នៃជំងឺសង្គមបន្តជាប់គ្នាដែលនៅក្នុងនោះពួកគេបង្ខំចិត្ត រស់នៅ។ សេចក្តីថ្លៃថ្នូរគឺជាមុខទី១ នៃអភិសមាចារ វាគឺជាទិន្នន័យមួយ និងភារកិច្ចមួយ ជាការសន្មត់ជាមុនដែលដឹកនាំការគោរពសិទ្ធិមនុស្ស វាក៏ជាកាតព្វកិច្ចមួយ និងការតស៊ូមួយ ពីព្រោះដើម្បីឲ្យបានវា គេត្រូវតែប្រយុទ្ធតស៊ូជានិច្ច វាក្លាយជាគត្តិយសជាការតាំងតំណែងដែលអាចឈ្នះ ប៉ុន្តែយើងក៏អាចបាត់បង់បានដែរ ។

ចំណងនៃភាពថ្លៃថ្នូរឆ្លុះបញ្ចាំងនៅក្នុងភាពផ្ទុយគ្នាជាស៊េរីមួយ ដូចជាសេរីភាពនិងសមភាពបុគ្គល និងពលរដ្ឋ ឯកជននិងសាធារណៈ ភាគច្រើននិងភាគតិច យុត្តិធម៌និងអធិបតេយ្យរបស់រដ្ឋ១០។ នោះគឺជាបញ្ញិកាមួយប្រភេទដែលហាក់ដូចផ្ទុយគ្នា៖ យោងតាមបញ្ញិកាទី១ ភាពថ្លៃថ្នូរគឺជាកេតនភណ្ឌសាកលរបស់បុគ្គល យោងតាមបញ្ញិកាទី២ ភាពថ្លៃថ្នូរគឺជាការទាក់ទងនឹងការទទួលស្គាល់ និងទំនាក់ទំនងនឹងអ្នកដទៃ និងក្រុមមួយសង្គមមួយនិងជីវិតរស់នៅរួមគ្នា។ ហើយបញ្ញិកាទាំងពីរនេះគឺបញ្ជាក់យ៉ាងច្បាស់រវាងគ្នានឹងគ្នាពីព្រោះបញ្ញិកាទាំងពីរនេះបាញ់ឆ្ពោះទៅរកសេរីភាព។ តាមការពិតភាពថ្លៃថ្នូរ គឺជានាមមួយទៀតនៃសេរីភាពដែលប្រែក្លាយយើងទៅជា ប្រធាននៃសិទ្ធិ ជាតួអង្គ ជាពលរដ្ឋសកម្ម និងដែលមានទំនួលខុសត្រូវនៃសង្គម។ ដោយហេតុផលនេះហើយ រាល់អាកប្បកិរិយាដែលរំលោភបំពានលើសេចក្តីថ្លៃថ្នូរ គឺសុទ្ធសឹងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

សេចក្តីថ្លៃថ្នូរគឺ សេចក្តីខុសប្លែកគេ ពីព្រោះវាធ្វើឲ្យមនុស្សប្លែកពីគេ និងស្វយ័តក្នុងការជ្រើសរើសដោយសេរីនូវខ្លឹមសារដែលគេចង់ផ្តល់ឲ្យជីវិតរបស់ពួកគេ។ សេចក្តីថ្លៃថ្នូររបស់ខ្ញុំ គឺខុសពីគេ ពីព្រោះខ្ញុំជាមនុស្សតែម្នាក់ឯងគត់ដែលដឹងថាសេចក្តីថ្លៃថ្នូរមានដល់ណា ប៉ុន្តែគឺជាស្ថាប័ននានាទេដែលត្រូវការការពារខ្ញុំនិងជានាចំពោះខ្ញុំ ។ មានចំណងមួយរវាងបុគ្គលនិងវប្បធម៌ ហើយយោងតាម ឡឺវីណាស៍ យើងឆ្លងកាត់ពី "ខ្ញុំត្រូវតែ" ទៅជា "ខ្លួនខ្ញុំត្រូវតែចំពោះឯង" អ្នកដទៃស្ថិតនៅក្នុងខ្លួនខ្ញុំ[១១] ។

## ការឱនថយនៃភាពថ្លៃថ្នូរក្នុងសង្គម

នៅពេលដែលគេនិយាយពីភាពថ្លៃថ្នូរ ជួនកាលគឺសំដៅទៅរកគត្តិយសវិញទេ។ប៉ុន្តែកត្តិយសដូចដែល ស៊ីម៉ូន វ៉ៃយ បានឲ្យកត់សម្គាល់ គឺជា "តម្រូវការចាំបាច់របស់ព្រលឹងមនុស្ស" ដែលមានផ្ទុយនៅការគោរព ពីព្រោះការគោរពនេះ"ដូចគ្នាចំពោះមនុស្សទាំងអស់ និងមិនចេះប្រែប្រួល "ចំណែកឯគត្តិយសមានការទំនាក់ទំនងទៅនឹងមនុស្សណាម្នាក់ជាក់លាក់ មិនត្រឹមតែដូច្នេះទេ ប៉ុន្តែត្រូវបានឃើញនៅភាពជិតខាងសង្គម។ ជាការពិតណាស់ការសង្ឃឹមលើខ្លួនឯងគឺមិនអាចញែកចេញដាច់ពីការសង្ឃឹមក្នុងសង្គមទេ។ ការទទួលស្គាល់ភាពថ្លៃថ្នូររបស់មនុស្សនៅកម្រិតសិទ្ធិមនុស្សនៅតែជាអរូបីកម្ម ល្គឹកណាដែលគេមិនលើកពីតម្លៃរូបីយ៍របស់មនុស្សម្នាក់ៗ នៅក្នុងសង្គមជាក់លាក់ណាមួយ៖ ដើម្បីអភិវឌ្ឍរូបភាពវិជ្ជមានមួយរបស់ខ្លួនឯងតើ

គេមិនត្រូវទទួលស្គាល់ចំពោះយើង នូវតម្លៃមួយនៅក្នុងវិស័យណាមួយទេឬ?១២។

ភាពថ្លៃថ្នូរគឺជាការទំនាក់ទំនងពីព្រោះគេត្រូវមានភាពថ្លៃថ្នូរជានិច្ចចំពោះអ្វីមួយ ឬចំពោះនរណាម្នាក់ដែលធៀបនឹងគេនោះ យើងយកខ្លួនយើងទៅធៀប។ ឪពុកម្តាយត្រូវតែមានភាពថ្លៃថ្នូរនឹងកូន កូនត្រូវតែថ្លៃថ្នូរជាមួយឪពុកម្តាយ គ្រូនឹងសិស្សត្រូវបង្ហាញថាខ្លួនមានភាពថ្លៃថ្នូរចំពោះភារកិច្ចអប់រំ ពួកគេមានកាតព្វកិច្ចលើភាពថ្លៃថ្នូរទៅវិញទៅមក។ ភាពថ្លៃថ្នូរមួយដែលឈរលើសិទ្ធិ មានន័យលុះត្រាតែយើងចេះធ្វើខ្លួនទៅតាមកាតព្វកិច្ចរបស់យើង គឺសេចក្តីថ្លៃថ្នូរនោះហើយ ដែលអនុញ្ញាតឲ្យយើងតស៊ូប្រឆាំងនឹងរាល់ការប្រែប្រួលនានាឲ្យយើងទាមទារការគោរពសម្រាប់មនុស្សទាំងអស់គ្នា ហើយក៏សម្រាប់ខ្ញុំ ដោយគ្មានលក្ខខណ្ឌពូជអំបូរពណ៌សម្បុរ ភេទ សាសនា អាយុ ។ល។ (មាត្រា២ នៃសេចក្តីប្រកាសសិទ្ធិមនុស្សជាសាកល)១៣ ។

ទិដ្ឋភាពទំនាក់ទំនងមានទំនាក់ទំនងទៅនឹងសមត្ថភាពសន្ទនា ការគោរព និងលើកតម្កើងនានាដើម្បីកុំបំលែង ភាពវប្បធម៌ សាសនា ជាតិពន្ធុ សង្គម និងនយោបាយទៅជាអបរិយាប័ន្ននិងការរើសអើងច្រើនយ៉ាង ។ ភាពថ្លៃថ្នូរ "អភិវឌ្ឍឡើងនៅក្នុងការវិវត្តក្នុងលំដាប់សង្គមវប្បធម៌ សេដ្ឋកិច្ចនិងគតិយុត្តិ ពីបុគ្គលទៅជាពលរដ្ឋ ជាការទទួលស្គាល់បន្តិចម្តងៗ និងរដ្ឋធម្មនុញ្ញកម្មសិទ្ធិចំពោះអ្នកដទៃ និងចំពោះរដ្ឋ១៤។ វាជាកាតព្វកិច្ចរបស់រដ្ឋ និងសហគមន៍អន្តរជាតិដែលត្រូវធានាសិទ្ធិទាំងអស់។ ភាពថ្លៃថ្នូរតំណាងឲ្យភាពសំយោគនៃសេរីភាព និងសមភាពដែលបង្កើតទៅជាលទ្ធិប្រជាធិបតេយ្យ១៥។ គឺជាគុណធម៌គ្រឹះរបស់បុគ្គល និងរបស់ជីវិតទំនាក់ទំនងរបស់ពួកគេ។ ភាពថ្លៃថ្នូរសង្គមសង្កត់ធ្ងន់ និងពង្រឹងប្រព័ន្ធទំនាក់ទំនងមួយដែលហ៊ុមព័ទ្ធបុគ្គល និងដែលផ្តល់ឲ្យបុគ្គលនោះនូវកម្លាំងធ្វើប្រតិកម្ម។ ដូចនេះសេចក្តីថ្លៃថ្នូរក្លាយជាមូលដ្ឋានគ្រឹះរូបីនៃភាពជាពលរដ្ឋ ដែលត្រូវគេមើលឃើញថាជាការអនុវត្តសិទ្ធិដែលជារបស់មនុស្សម្នាក់ៗ។ ការរំលោភសិទ្ធិទាំងនេះ គឺជាការរំលោភគោលការណ៍នៃសេចក្តីថ្លៃថ្នូរ ហើយក្នុងចំណោមសិទ្ធិទាំងអស់ជាពិសេសសិទ្ធិវប្បធម៌ "ដាក់ឲ្យប្រឈមដោយផ្ទាល់នូវសេចក្តីថ្លៃថ្នូររបស់មនុស្ស និងត្រូវទទួលស្គាល់ចំពោះមនុស្សគ្រប់រូបរួមទាំងជនក្រីក្រផងដែរ។ ពួកវាការពារជាពិសេសទិដ្ឋភាពនៃសេចក្តីថ្លៃថ្នូរនេះ ដែលជាអត្តសញ្ញាណ"១៦។ ជីវិតមួយគ្មានភាពថ្លៃថ្នូរគ្មានការគោរពគឺជាជីវិតមួយដែលត្រូវបានបំផ្លាញសមត្ថភាពតបស្វ័យសម្រេច បញ្ចេញមតិ និងជ្រើសរើសការអភិវឌ្ឍផ្ទាល់របស់ខ្លួន ។ ជីវិតនយោបាយនិងជីវិតសង្គម គឺជាលក្ខណៈមួយ និងជាការស្តែងចេញនូវភាពថ្លៃថ្នូររបស់មនុស្សក្នុងលក្ខខណ្ឌដែលវាឈរនៅលើភាពជាក់ស្តែងនៃសិទ្ធិសម្រាប់បុគ្គលម្នាក់ៗ៖ តើជនជាតិភាគតិច ជនភៀសខ្លួនអ្នកសុំសិទ្ធិជ្រកកោន ជនផ្លាស់ទីដែលធ្វើសក្ខីកម្មពីការរំលោភជាច្រើនទៅលើសិទ្ធិទាំងនេះមានតួនាទី និងការទទួលស្គាល់អ្វីទៅ? ស្ទើរតែជានិច្ចជាកាលទៅហើយ ដែលពួកគេត្រូវបានគេដាក់នៅក្រៅសហគមន៍ហើយរស់នៅដោយគ្មានសហគមន៍ មានន័យថារស់នៅដោយគ្មានភាពថ្លៃថ្នូរ។ កន្លែងតែមួយគត់ដែលសេចក្តីថ្លៃថ្នូរ

បុគ្គល និងសង្គមអាចអនុវត្តបាន និងអាចត្រូវគេគោរព គឺជីវិតសង្គម និងនយោបាយពីព្រោះគឺនៅទីនេះ ហើយដែលអធិបតេយ្យលាតត្រដាងឡើង។ មានអធិបតេយ្យ ប្រសិនបើមានការចូលរួមនៅក្នុងសហគមន៍ ប្រសិនបើមានការប្រែក្លាយសិទ្ធិមនុស្សទៅជាសកម្មភាពរូបី ប្រសិនគេអាចរស់នៅទីកន្លែងដែលយើងតាំងនៅ ប្រសិនបើមានការទទួលស្គាល់ទៅវិញទៅមកមួយរវាងបុគ្គល និងសាមគ្គីភាពមួយរវាងសង្គមនានា។

អធិបតេយ្យគឺជាការអនុវត្តនូវសារពើនៃសិទ្ធិមនុស្ស (ជាមួយនឹងសេរីភាពនិងទំនួលខុសត្រូវដែលនៅជាប់ជាមួយ) ដោយបុគ្គលនានានៅក្នុងសហគមន៍នយោបាយ ដែលត្រូវបានកំណត់ថាជាសហគមន៍ប្រជាធិបតេយ្យ[១៧]។ ចំណោមនយោបាយនៃភាពថ្លៃថ្នូររបស់មនុស្ស គឺជាបញ្ហាប្រឈមមួយ និងជាការសន្យាសង្គមមួយសម្រាប់មនុស្សទាំងអស់គ្នា ពីព្រោះយើងទាំងអស់គ្នាត្រូវតែជាកូនបំណុលនៃសិទ្ធិ និងតស៊ូប្រឆាំងដើម្បីសេចក្ដីថ្លៃថ្នូរការងារ លំនៅស្ថាន និងស្បៀងអាហារ។ល។ តាមរយៈការវាយតម្លៃសមិទ្ធិកម្មនៃសិទ្ធិជាសារវន្ត ដែលគេអាចវាស់វែងដឹងពីគុណភាពគោលនយោបាយបាន។ គ្មានស្ថាប័នណាមួយគ្មាន "ច្បាប់" សេដ្ឋកិច្ច សង្គម វប្បធម៌ ឬហេតុផលរដ្ឋណាអាចស្ថិតនៅពីលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស ឬបោះបង់ចោលសេចក្ដីថ្លៃថ្នូរនេះបានទេ។

សេចក្ដីថ្លៃថ្នូរស្ដែងឡើងនៅក្នុងសមិទ្ធិកម្មនៃទ្រព្យសម្បត្តិសមូហភាពមួយ ថ្មីៗនេះសញ្ញាណនៃ "ទ្រព្យសមូហភាព" បានទទួលឡើងវិញនូវតួនាទីដ៏សំខាន់បំផុតនៅក្នុងការពិចារណា ស្ដីពីអធិបតេយ្យភាពប្រជាជន និងស្ដីពីអភិបាលកិច្ចប្រជាធិបតេយ្យ[១៨]។ សញ្ញាណនេះត្រូវបានគេលើកឡើងយ៉ាងខ្លាំងនៅកម្រិតផ្សេងៗ នៅក្នុងកិច្ចពិភាក្សារបស់អ្នកឯកទេសមុខវិជ្ជាសេដ្ឋកិច្ច ច្បាប់ និងទស្សនវិទូដែលបានឃើញភាពចាំបាច់ក្នុងការស្វែងរកឲ្យឃើញនូវគោលគំនិតមួយ ដែលអាចនឹងតំណាងឲ្យការកែប្រែគំរូនៅក្នុងការកំណត់គោលនយោបាយនានាសម្រាប់ការអភិវឌ្ឍដោយបរិយាប័ន្នមួយ[១៩]។ សញ្ញាណនេះស្ថិតនៅក្នុងបរិបទអន្តរជាតិមួយ ដែលនៅក្នុងនោះកម្មសិទ្ធិ/ផលប្រយោជន៍សេដ្ឋកិច្ចកាន់តែបានចំណេញឥទ្ធិពលនៅក្នុងការពិចារណាស្ដីពីការអភិវឌ្ឍ។

នៅក្នុងសម័យកាលមួយដែលសង្គមអន្តរជាតិ កំពុងត្រៀមខ្លួនធ្វើការឯកភាពទៅលើគោលដៅថ្មីៗសម្រាប់ការអភិវឌ្ឍយូរអង្វែងនោះ (Sustainable Development Goals ) សម្ដេចប៉ាបហ្វ្រង់ស៊ីសកាលពីឆ្នាំ ២០១៤ បានកោះអញ្ជើញអ្នកទទួលខុសត្រូវនយោបាយ អ្នកសេដ្ឋកិច្ច និងចិន្តបណ្ឌិតដែលមានឥទ្ធិពលមួយក្រុមឲ្យចូលរួមក្នុង សន្និសិទមួយដែលមានចំណងជើងថា "ទ្រព្យសមូហភាពពិភពលោក៖ ឆ្ពោះទៅរកសេដ្ឋកិច្ចមួយដែលកាន់តែមានបរិយាប័ន្ន[២០]។ សម្ដេចប៉ាប ហ្វ្រង់ស៊ីស បានធ្វើការថ្កោលទោសចំពោះការកាត់បន្ថយនិយមនវិទ្យា នៅក្នុងសេដ្ឋកិច្ចដែលសំដៅទៅរកប្រពៃណីមួយនៃលទ្ធិសង្គមកាតូលិកដែលផ្សារភ្ជាប់បរិយាប័ន្នសេដ្ឋកិច្ចទៅនឹង សេចក្ដីថ្លៃថ្នូររបស់មនុស្ស។

សម្តេចបានរំឮកថា ជារឿយៗមនុស្សត្រូវបានគេចាត់ទុកថាជាមធ្យោបាយមួយក្នុងលំដាប់សេដ្ឋកិច្ច ពុំមែនជាហេតុផលដើម្បីឲ្យសកម្មភាពសេដ្ឋកិច្ចមានដំណើរការឡើយ[២១] ជាពិសេសប្រសិទ្ធភាព និង ល្បឿននៃអន្តរការណ៍ហរិញ្ញវត្ថុមិនគួរណាក្លាយទៅជាគោលដៅចុងក្រោយ ប៉ុន្តែគួរតែជាតម្លៃកណ្តាលដែលចាំបាច់ត្រូវតែមានភាពសុខដុមជាមួយនឹងគុណតម្លៃជាសារវន្ត ដូចជាការបន្ថែមការប្រុងប្រយ័ត្នស្លេះភាព និងទ្រព្យសម្បត្តិសមូហភាពនៅក្នុងអត្ថន័យ នៃសេវាកម្មមួយសម្រាប់ការអភិវឌ្ឍមនុស្សដែលមានសមាហរណកម្ម[២២] ។ ផ្ទុយពីសាកលភាវូបនីយកម្មមួយ ដែលនាំមកនូវភាពប្រសព្វសេដ្ឋកិច្ចយឺត ប៉ុន្តែបន្តិចម្តង សន្សឹមៗរវាងរដ្ឋនិងរដ្ឋ។ នៅចុងក្រោយសម្តេចប៉ាបបានលើកឡើងពីភាពចាំបាច់នៃចក្ខុវិស័យមួយពេញលេញរបស់មនុស្ស និងពិភពលោកដែលជាធាតុសារវន្តនានានៃរាល់សកម្មភាពសេចក្តីសម្រេច នយោបាយនិងសង្គម។

សញ្ញាណនៃទ្រព្យសម្បត្តិសមូហភាពទាមទារម៉្យាងនៅគំរូឆ្លាស់មួយ របៀបនៃការរៀបចំ ការចូលរួម និង អភិបាលកិច្ចដែលចុងក្រោយ អាចឲ្យគេសង្ឃឹមពីការអភិវឌ្ឍប្រកបដោយបរិយាប័ន្នមួយ ដែលឈរនៅលើភាពថ្លៃថ្នូររបស់មនុស្សដែលជាសារជាតិនៃសិទ្ធិមនុស្ស ។

**និយមន័យ "ទ្រព្យសម្បត្តិរួម"** [២៣]

ដោយយោងទៅលើទ្រព្យសម្បត្តិសមូហភាព វាជាការសំខាន់ណាស់ដែលត្រូវបញ្ជាក់លម្អិតពីចរិតលក្ខណៈដែលញ៉ាំងឲ្យសញ្ញាណនេះ សំខាន់ដើម្បីចងក្រងរចនានូវអភិបាលកិច្ចប្រជាធិបតេយ្យដែលកែប្រែជាថ្មី ផ្អែកលើការចូលរួមសកម្មរបស់សហគមន៍ ។

សញ្ញាណ "ទ្រព្យសម្បត្តិសមូហភាព" អាចត្រូវចាត់ទុកថាជាគោលគំនិតសីលធម៌ ជាចក្ខុវិស័យសីលធម៌មួយនៃអ្វីដែលស្ថិតនៅក្នុងផលប្រយោជន៍នៃសង្គម។ ម៉្យាង "ទ្រព្យសម្បត្តិសមូហភាព" ត្រូវបានកំណត់និយមន័យថា ជាទ្រព្យដែលកំណត់ដោយគោលដៅរួមមួយ ទោះជាសាធារណៈឬឯកជនក្តីនិងចាំបាច់ដើម្បីសមិទ្ធកម្មនៃសិទ្ធិជាសារវន្តរបស់មនុស្សទាំងអស់[២៤]។ ទ្រព្យសម្បត្តិសមូហភាពត្រូវបាន "បង្កើតឡើងដោយទ្រព្យសម្បត្តិដែលមនុស្សចែករំលែកគ្នាជាសជ្ឈន្តិកៈ និងបញ្ចូលទៅមករវាងគ្នានិងគ្នា ដូចជាគុណតម្លៃ គុណធម៌ជាពលរដ្ឋ និងអត្ថន័យនៃយុត្តិធម៌"[២៥]។ វាគឺជាសមាគមសាមគ្គីមួយនៃបុគ្គលលើសពីទ្រព្យសម្បត្តិរបស់ឯកត្តជននៅក្នុងសារពើរបស់វា។ ជាទ្រព្យសម្បត្តិដែលត្រូវក្លាយទៅជាសហគមន៍មួយទ្រព្យសម្បត្តិដែលគេឈានទៅដល់នៅក្នុងទំនាក់ទំនងទៅវិញទៅមកដែលនៅក្នុងនោះ និងតាមរយៈនោះមនុស្សចូលទៅដល់សុខមាលភាពរបស់ពួកគេ។ "ទ្រព្យសម្បត្តិរួម" ក៏ត្រូវកំណត់ថា "ទ្រព្យធនជានមិនមែនឯកជនហើយមិនមែនជាសាធារណៈ និងចែករំលែកគ្រប់គ្រងដោយសហគមន៍មួយ ដែលកំណត់សិទ្ធិប្រើប្រាស់ទ្រព្យនោះ (សិទ្ធិទទួលបាន សិទ្ធិចែករំលែក សិទ្ធិធ្វើចរាចរណ៍...)[២៦] ហេតុដូចនេះទ្រព្យ

សម្បត្តិរួមគឺនៅជាប់នឹងទំនាក់ទំនងដែលមានស្រាប់ រវាងសមាជិកនានានៃសង្គមមួយដែលភ្ជាប់ទាក់ទិនរវាងគ្នានឹងគ្នានៅក្នុងការខំប្រឹងប្រែងរួមមួយ។ ដូច្នោះជាសង្ឃន្និកៈទ្រព្យសម្បត្តិប្រភេទនេះ គឺសមូហភាពនៅក្នុងផលិតកម្មរបស់វា ព្រមទាំងនៅក្នុងអត្ថប្រយោជន៍របស់ពួកវា[២៧]។

**ជាទូទៅសញ្ញាណទ្រព្យសម្បត្តិរួមត្រូវកំណត់ដោយចរិតលក្ខណៈដូចខាងក្រោម៖**

-ទិដ្ឋភាពសមូហភាព៖ លើទស្សនៈនៃ "ទ្រព្យសម្បត្តិរួមមិនមែនត្រឹមតែជីវិតសុខដុមរបស់បុគ្គលមនុស្សទេ ដែលសំខាន់នោះប៉ុន្តែក៏ជាភាពសុខដុមនៃជីវិតដែលមនុស្សមានជាសមូហភាពដែរ[២៨]។ វាមិនមែនជាទ្រព្យបុគ្គល មិនមែនជាទ្រព្យមួយដែលជាកម្មសិទ្ធិរបស់ក្រុមតូចមួយដែរ[២៩]។ ដូច្នេះទ្រព្យសមូហភាពអះអាងបញ្ជាក់ឡើងវិញ ពីទិដ្ឋភាពសមូហភាពក្នុងនាមជាសហគ្រាសសង្គមសមូហភាព។

-នានាភាព៖ យើងមិនអាចកំណត់និយមន័យទ្រព្យសម្បត្តិសមូហភាពតែតាមរយៈនានាភាពនៃបរិបទ និងទស្សនទាននៃសុខមាលភាព និងជីវិតសមូហភាពទេ។ ដូច្នេះសហគមន៍នីមួយៗនិងមានការយល់ផ្ទាល់ទៅលើបរិបទពិសេសមួយនៃទ្រព្យសម្បត្តិសមូហភាព[៣០]។ ដោយហេតុតែនានាភាពនៃការបកស្រាយ វប្បធម៌នៃអ្វីៗដែលបង្កើតទៅជាទ្រព្យសម្បត្តិសមូហភាពមួយ គោលនយោបាយសាធារណៈត្រូវតែយកចិត្តទុកដាក់ និងអនុគ្រោះដល់នានាភាពនៃបរិបទ ចក្ខុវិស័យចំពោះពិភពលោក និងប្រព័ន្ធចំណេះដឹងដោយទាំងគោរពសិទ្ធិជាសារវន្ត[៣១] ។

-ដំណើរការចូលរួម៖ គោលគំនិតនៃទ្រព្យសម្បត្តិសមូហភាពសង្កត់ធ្ងន់ទៅលើការចូលរួម ដែលការចូលរួមនេះជាទ្រព្យសមូហភាពថ្មីមួយដែរ។ សកម្មភាពចែករំលែកគឺមានភាពសង្ឃន្និកៈ ព្រមទាំងជាឧបករណ៍សម្រាប់ទ្រព្យសម្បត្តិនោះ[៣២]។ ដូច្នេះទ្រព្យសម្បត្តិសមូហភាព ចាំបាច់ត្រូវមានដំណើរការបរិយាប័ន្នមួយនៃការរចនាបង្កើត និងប្រតិបត្តិគោលនយោបាយសាធារណៈ។ ដាក់ទ្រព្យសម្បត្តិសមូហ-ភាពហួសពីការបែងចែកមែកធាង រវាងមជ្ឈដ្ឋានសាធារណៈ និងមជ្ឈដ្ឋានឯកជនត្រូវការការរចនា និងងាកទៅរកទម្រង់ថ្មីៗ (និងស្ថាប័ន) នៃប្រជាធិបតេយ្យបែបចូលរួម ។

-អភិសមាចារនិងទំនួលខុសត្រូវ៖ ទ្រព្យសម្បត្តិសមូហភាពគឺទ្រព្យសម្បត្តិ សំខាន់លើភាពមានរូបរាងជាជាងការដែលមានកម្មសិទ្ធិ[៣៣]។ គោលគំនិតនេះប្រានចោលទាំងស្រុងនៅចំណុចប្រសព្វនៃប្រធានវត្ថុព្រមទាំងនូវរាល់គោលវិធីសេដ្ឋកិច្ចកាត់បន្ថយនិយមនិងបរិមាណ។ គំរូជាប្រពៃណីបង្ហាញពី "តក្កវិជ្ជានៃការមានកម្មសិទ្ធិ" ដែលបដិសេធមិនបង្ករជាបញ្ហាដល់លក្ខខណ្ឌនៃលទ្ធភាព នៃសកម្មភាពរបស់បុគ្គលឯកជននៅក្នុងពិភពលោក។ ផ្ទុយពីនេះសញ្ញាណនៃទ្រព្យសម្បត្តិសមូហភាពដែលនៅក្នុងរង្វាស់ខ្លះអាចបង្កើតទៅជាការប្រែប្រួលគំរូនោះ ដាក់ឲ្យនៅចំកណ្ដាលឡើងវិញនូវគុណតម្លៃនិងសេចក្ដីថ្លៃ

ផ្ទៃរបស់មនុស្ស ក្នុងនាមជាតុជាសារវន្តសម្រាប់សមិទ្ធកម្មសុខមាលភាព។ ដោយផ្អែកលើការទំនាក់ទំនងដែលមនុស្សបង្កើតជាមួយធនធានទ្រព្យសម្បត្តិសមូហភាព តំណាងឲ្យទាំងប្រពន្ធ័គុណតម្លៃ និងទំនួលខុសត្រូវចែករំលែកមួយ ជាមួយនឹងការសន្យាដែលអនុគ្រោះដល់ការសាមគ្គីភាព។ "បុគ្គលម្នាក់ៗទាំងជាឯកត្តជន និងនៅក្នុងចំណោមតួអង្គបីប្រភេទ ជាជនស៊ីវិល សាធារណៈ និងឯកជនមានចំណែកទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិសមូហភាព ដែលអាចត្រូវកំណត់ថាជាការទទួលបានសិទ្ធិមនុស្សរបស់មនុស្សម្នាក់ដែលគេមិនអាចបង្កើតឡើងបាន ដោយគ្មានប្រព័ន្ធសង្គមដែលញ៉ាំងឲ្យបានជាអតិបរមានៅសេរីភាពរួម និងទំនួលខុសត្រូវរួម"[៣៤]។

## ទ្រព្យសម្បត្តិសមូហភាព អត្តសញ្ញាណវប្បធម៌ និងភាពថ្លៃថ្នូរ

ទិដ្ឋភាពសមូហភាពនៃទ្រព្យសមូហភាព តំណាងឲ្យចំណុចសារវន្តនៃដំណើរការធ្វើឲ្យស័ក្តិសមឡើងវិញ នៃសេចក្តីថ្លៃថ្នូរបុគ្គលឬសមូហភាព។ តាមការពិតទ្រព្យសម្បត្តិសមូហភាពកើតឡើងទៅតាមភាពចាំបាច់ក្នុងការធានាការចូលរួមរបស់សហគមន៍ នៅក្នុងការគ្រប់គ្រងធនធានសម្ភារនិងចំណេះដឹងដែលមានន័យថាជាការបញ្ជាក់អះអាងឡើងវិញនៅចំណាងសាមគ្គីភាពសង្គមដែលធ្វើឲ្យទន់ខ្សោយ ឬមានផលប៉ះពាល់ដើម្បីបង្កើតចំណាងថ្មីវិញ[៣៥]។ ទ្រព្យសម្បត្តិសមូហភាព តាមពិតទៅជាធនធានទាំងឡាយដែលជាមួយនឹងធនធាននោះ មនុស្សមួយក្រុមរក្សាទំនាក់ទំនងរស់រវើកមានន័យថាទម្រង់អាចស្គាល់នៃគំនិត ការពិភាក្សានិងការធ្វើសេចក្តីសម្រេច[៣៦] ដោយបង្ហាញទម្រង់នៃចំណេះដឹងមួយ សញ្ញាណនេះក៏បង្ហាញ ទម្រង់នៃសម្បជញ្ញៈដែលនៅក្នុងនោះចំណេះដឹងកើតឡើងជារចនាសម្ព័ន្ធ។ ការងារនៅជុំវិញសមូហភាពច្រើន(ទ្រព្យសម្បត្តិសមូហភាពនានា)ក្លាយទៅជាការងារនៅជុំវិញសមូហភាពមួយ(ទ្រព្យសម្បត្តិសមូហភាពមួយ)ដែលជាការបង្ហាញនូវឆន្ទៈនៃសម្បជញ្ញៈជាច្រើន ដែលស្ថិតនៅក្នុងសហគមន៍ ឬសមូហភាពមួយដូចគ្នា។

ចាំបាច់សម្រាប់សមិទ្ធកម្មនៃសិទ្ធិជាសារវន្តរបស់មនុស្ស ជាពិសេសសិទ្ធិវប្បធម៌ ទ្រព្យសមូហភាពអាចត្រូវចាត់ទុកថាជាមន្ទីរពិសោធនៃការអភិវឌ្ឍសមត្ថភាព សេរីភាព និងទំនួលខុសត្រូវរួម នេះបើយោងទៅតាមគំរូមួយនៃការអភិវឌ្ឍដែលឈរនៅលើសិទ្ធិមនុស្ស[៣៧]។ ទ្រព្យសមូហភាពជាកាតាលីករ និងតំណាងឲ្យអត្តសញ្ញាណវប្បធម៌របស់សហគមន៍មួយ ខ្លឹមសាររបស់វានិយមន័យរបស់វានៅក្នុង និងតាមរយៈនោះវាទទួលស្គាល់ខ្លួនឯង បង្កើតខ្លួនឯង និងបង្កើតខ្លួនឯងឡើងវិញ[៣៨]។ ប៉ុន្តែទ្រព្យទាំងនេះ ក្លាយទៅជាបរិបទសមិទ្ធកម្មនៃសិទ្ធិជាសារវន្ត និងជាងនេះទៅទៀត សិទ្ធិវប្បធម៌ដែលបង្ហាញពីសេចក្តីរបស់មនុស្ស និងសហគមន៍។ ជាការចាំបាច់ដែលសិទ្ធិវប្បធម៌ត្រូវបានគេគោរព ហើយទ្រព្យសម្បត្តិសមូហភាពត្រូវ បង្កើតឡើងដើម្បីឲ្យអត្តសញ្ញាណវប្បធម៌អាចមានសមិទ្ធិកម្មជា "សំណុំនៃភាពយោងវប្បធម៌ ដែលតាមរយៈនោះ បុគ្គលម្នាក់ៗ ទាំងម្នាក់ឯងឬសមូហភាព កំណត់និយមន័យខ្លួនឯង បង្កើតខ្លួនឯងនូវទំនាក់ទំនងនិងចង់ឲ្យ

គេទទួលស្គាល់នៅក្នុងសេចក្តីថ្លៃថ្នូររបស់ខ្លួន[៣៩] ។

ទ្រព្យសម្បត្តិសមមូហភាពក្លាយទៅជាមន្ទីរពិសោធគ្មានដំបូល ដែលអនុញ្ញាតឲ្យមាន "មានការងារស្ថាប័ន" ពិតប្រាកដមួយដើម្បីកំណត់គោលនយោបាយសាធារណៈ ដែលគោរពសិទ្ធិសារវន្តជាពិសេសសិទ្ធិវប្បធម៌ដែលជាការសម្តែងនូវសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ដូច្នេះភាពជាសមូហភាពអាចត្រូវចាត់ថាជាគោលការណ៍ថ្មីមួយ នៃលទ្ធិប្រជាធិបតេយ្យបែបចូលរួម ដែលចេញពីនោះគេអាចបង្កើតទៅជាទ្រព្យសម្បត្តិសមូហភាព និងយោងទៅទ្រព្យទាំងនោះ ដើម្បីអភិរក្សវាទុកពង្រីកនិងធ្វើឲ្យវារស់រានបាន[៤០]។ ទ្រព្យទាំងនេះក្លាយទៅជាការសម្តែងអត្តសញ្ញាណនៃសហគមន៍មួយ និងអនុញ្ញាតឲ្យមានការគោរពសេចក្តីថ្លៃថ្នូររបស់ខ្លួន។ "គ្មានស្ថាប័នណា ច្បាប់សេដ្ឋកិច្ច សង្គម វប្បធម៌ ឬហេតុផលរដ្ឋណាអាចស្ថិតនៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ឬបោះបង់វាចោលនោះទេ ។ តួអង្គត្រូវតែចេះចែករំលែកគោលការណ៍នានា និងអំណាចធ្វើឲ្យមានអន្តរកម្មចំពោះនានាភាព ដើម្បីបង្កើតបានលក្ខខណ្ឌនានានៃការអភិវឌ្ឍប្រកបដោយសមធម៌ ដែលនៅក្នុងនោះរាល់បុគ្គលដែលត្រូវគេទទួលស្គាល់នៅក្នុងសេចក្តីថ្លៃថ្នូរ និងនៅក្នុងអត្តសញ្ញាណ អាចអភិវឌ្ឍខ្លួនបាននៅក្នុងជាលិការនៃអន្តរកម្មបាន"[៤១]។ នេះអាចកើតឡើងជាក់ស្តែងបាននៅក្នុងការចូលរួមរបស់តួអង្គទាំងអស់នៅក្នុងការកំណត់ពីទ្រព្យសម្បត្តិសមូហភាព។ តាមរយៈដំណើរការបែបចូលរួមនេះប៉ុណ្ណោះដែលសហគមន៍មួយអាចធ្វើឲ្យស័ក្តិសមនឹងសេចក្តីថ្លៃថ្នូរផ្ទាល់របស់ខ្លួន និងបង្កើតសង្គមមួយដែលថ្មីផ្អែកទៅលើគុណតម្លៃ និងទៅលើអត្តសញ្ញាណនៃសហគមន៍ដូចគ្នានេះ។

# ១ សេចក្តីថ្លៃថ្នូររបស់មនុស្ស និងសមិទ្ធិកម្មទ្រព្យសម្បត្តិរួម

## Dignité de la personne et réalisation du bien commun”

**Prof. Stephania Gandolfo Bergamo/Italy**

Selon le philosophe Paul Ricoeur le concept de dignité renvoie à l’idée que « quelque chose est dû à l'être humain du fait qu'il est humain » . En fait l’ethimologie du mot dignitas dit ce qui rend digne, dit vertu, honneur, considération, estime, et la dignitas nous renvoie tantôt au respect que mérite une personne humaine, tantôt au respect dû à soi-même.

La dignité n’est ni un idéal ni un objectif; elle est un principe qui preside la vie de chacun et, en tant que principe, elle n’est pas négociable parce que il prende en compte la personne considerée dans sa singularité, dans sa capacité de se determiner et de se referer aux autres en conséquence. Un principe selon lequel une personne ne doit jamais être traitée comme un objet ou comme un moyen, mais comme un fin et une entité intrinsèque. « Ce qui permet que quelque chose soit un fin en soi n’a pas seulement une valeur relative , c’est-à-dire un prix, mais il a aussi la une valeur intrisèque et c’est-à-dire une dignité” … “L’umanité est elle même une dignité: l’homme ne peut pas être traité comme un simple moyen mais toujours comme un fin: En cela consiste sa dignité” .

La dignité est, en soi, valeur, parce qu’elle dit l’humain, elle dit la ressource et la valeur intriséque et donc force de la pensé qui fait de l’homme une valeur à respecter et une valeur immanente à protéger. Pour Pascal la dignité consiste dans la pensée « L’homme n’est qu’un roseau, le plus faible de la nature mais c’est un roseau pensant. Toute notre dignité consiste en la pensée. C’est là qu’il nous faut relever et non de l’espace et de la durée que nous ne saurions remplir. Travaillons donc à bien penser : voilà le principe de la morale»

Dans un monde où toute relation, pour être viable, entre dans le « système de la marchandise », là où tout s’achète et où tout se vend, la dignité humaine est de «l’ordre du sans prix » .

La concept de dignité est liée à celui de respect et d’humiliation qui implique la reconnaissance respectueuse de soi même et de l’Autre; elle est inspirée par un désir de respectabilité et traduit le sentiment que la personne a de sa propre valeur. Le respect vise à protéger les aspects interdépendants et multiples de la personne allant de son intégrité corporelle, à son intégrité morale et à son épanouissement personnel; un respect inconditionné, indépendamment de l’âge, du sexe, de l’état de santé physique ou mentale, de la condition sociale, de la religion ou de l’origine ethnique.

La dignité trouve sa reconnaissance politique et juridique dans la Déclaration Universelle des Droits de l'Homme de 1948 qui réconnaît que tous les êtres humains possèdent une

"dignité inhérente" (Préambule) ". On lit dans le Preambule que la dignité constitue « le fondement de la liberté, de la justice et de la paix dans le monde » et on souligne son universalité qui se traduit dans la parité des droits et ces droits ouvrent aussi une perspective à la réalisation de toutes les communautés et les sociétés.
៣/ ព្រះជាម្ចាស់បង្កើតយើងឲ្យមានប្រាជ្ញាស្មារតីមាំមួនល្អណាស់ ដែលអាចបង្កើតអ្វីៗបានទាំងអស់ ដូច្នេះ ចាំបាច់យើងត្រូវតែការពារប្រាជ្ញាស្មារតីរបស់យើងឲ្យបានល្អ។ កាលណាយើងការពារបានល្អហើយ យើងអាចប្រើវាដើម្បីរួមចំណែកក្នុងការកសាងសង្គមឲ្យមានការអភិវឌ្ឍឲ្យមានស្ថេរភាព។ បើយើងខ្វះការការពារប្រាជ្ញាស្មារតីរបស់យើងនោះហាក់បីដូចយើងបំផ្លាញសង្គមដែរ។ ការពារប្រាជ្ញាស្មារតីមានចំណុចមួយចំនួនដូចជា៖

- ទីមួយ កុំពិសាស្រាព្រោះស្រាវាពង្វក់ស្មារតី។ ស្រាបង្កើតបញ្ហាក្នុងគ្រួសារ ក្នុងទំនាក់ទំនងជាមួយមិត្តភ័ក្តិដែរ។
- ទីពីរ មិនត្រូវសេពគ្រឿងញៀនដែលមិនត្រឹមតែបំផ្លាញខ្លួនឯងប៉ុណ្ណោះទេ តែវាបំផ្លាញសេដ្ឋកិច្ចគ្រួសារទៀត។ សំខាន់បំផុតគឺមេដឹកនាំសាសនា ត្រូវតែគោរពឲ្យបានតាមគម្ពីររបស់ខ្លួន។
- ទីបី ត្រូវចេះរក្សាពូជពង្សសាវតា។ បើយើងទៅទាក់ទងនារីណាម្នាក់មករួមបវេណី តើយើងបានគិតទេថាបើមានគេប្រព្រឹត្តបែបនេះមកលើបងប្អូនយើង លើម្តាយយើងតើយើងមានអារម្មណ៍បែប ណា?។ បើមនុស្សគ្រប់គ្នាគិតបែបនេះការជួញដូរមនុស្ស ការចម្លងជំងឺអេដស៍លែងមានទៀតហើយហើយវានឹងរួមចំណែកក្នុងការកសាងសង្គមការពារស្ថេរភាពសង្គម ថែមទាំងជួយដល់កំណើនសេដ្ឋកិច្ចសង្គមទៀតផង។
- ទីបួន ត្រូវចេះការពារខ្លួនដោយមិនប្រព្រឹត្តអំពើគួរឲ្យអៀនខ្មាស។ ត្រូវផ្តល់កិត្តិយសឲ្យខ្លួនដោយរស់នៅក្នុងភាពថ្លៃថ្នូរ។ ត្រូវការពារមាត់កុំឲ្យនិយាយដើមគេ ការពារចិត្តកុំឲ្យឈ្នានីសអ្នកដទៃការបំផ្លាញអ្នកដទៃ កុំច្រណែនអ្នកដទៃ។ ត្រូវដឹងថាខ្លួនយើងនៅទន់ខ្សោយដែលត្រូវខិតខំបន្ថែមទៀតដើម្បីឲ្យបានដូចអ្នកដទៃដែលគេមាំមួនជាងយើង។ នេះជាការរួមចំណែកក្នុងការកសាងសង្គម។ គោលការណ៍របស់សាសនាអ៊ីស្លាមដែលនាំទៅរកស្ថេរភាពគឺការសន្ទនា។
- ទីប្រាំ កុំឲ្យទ្រព្យដែលយើងរកបានក្លាយទៅ ជាអាវុធសម្លាប់យើងនោះយើងត្រូវគិតអំពីរបៀបចំណាយ។អ្វីដែលយើងមិនចាំបាច់យើងមិនត្រូវចំណាយឡើយ ដូចជាទៅលេងល្បែងស៊ីសងទៅស៊ីផឹកស្រីញីដែលណែនាំឲ្យយើងអស់ទ្រព្យ និងបង្កើតទៅជាហិង្សាក្នុងគ្រួសារទៀតផង។

អស់អ្នកដែលព្រះជាម្ចាស់ផ្តល់ជម្រកឲ្យជ្រកកោននៅក្នុងផែនដីនេះមានកាតព្វកិច្ចៈ

- **ទីមួយ** ត្រូវគោរពព្រះដឹងគុណព្រះ។ អ៊ីស្លាមបរិស័ទ គោរពព្រះតាមកំណត់ដូចតទៅៈ

    គោរពទី១នៅពេលចេញទៅរកស៊ី

    គោរពទី២បន្ទាប់ពេលថ្ងៃត្រង់

    គោរពទី៣ថ្ងៃបាក់រសៀលពេលម៉ោង៣:៣០

    គោរពទី៤ពេលថ្ងៃលិច

    គោរពទី៥មុនពេលចូលគេង។ រយៈពេលគោរពម្តងៗ១០នាទី។

- **ទីពីរ** ត្រូវបរិច្ចាគទានដល់អ្នកក្រ។ តាមគោលការណ៍របស់សាសនាអ៊ីស្លាម មួយឆ្នាំត្រូវធ្វើទានម្តងប៉ុន្តែមិននិយាយអំពីការធ្វើទានផ្សេងៗទៀតឡើយ ។មុនធ្វើទាន តម្រូវឲ្យបរិស័ទអ៊ីស្លាមបួសជាមុនសិនដើម្បីយល់ដឹងជាក់ស្តែងពីការលំបាក។ រយៈពេលបួសមួយខែដោយតម្រូវឲ្យបរិភោគអាហារខុសទម្លាប់ពេលដែលធ្លាប់ហូបពេលថ្ងៃមកហូបនៅពេលយប់វិញ។ មូលហេតុដែលធ្វើដូច្នេះ ដើម្បីឲ្យយើងយល់ដឹងថានៅពេលយើងអត់អាហារតើយើងមានការលំបាករបៀបណាខ្លះ? គ្រាន់តែយើងដូរពេលហូបអាហារ យើងពិបាកប៉ុណ្ណឹងទៅហើយ តើគេលំបាកប៉ុណ្ណា?។ ពេលយើងស្គាល់ទុក្ខវេទនារបស់អ្នកក្រហើយ នោះយើងនឹងដាក់ទានដោយចិត្តស្មោះ។
- **ទីបី** ត្រូវចេះអប់រំគ្នាឲ្យធ្វើអំពើល្អ។
- **ទីបួន** ត្រូវចេះជួយការពារគ្នាពីអំពើអាក្រក់។

សរុបសេចក្តីមក មានតែការអប់រំឲ្យស្គាល់ខុសត្រូវទេដែលណែនាំឲ្យមនុស្សប្រព្រឹត្តអំពើល្អបាន។ យើងត្រូវតែរៀនតាំងពីតូចរហូតដល់យើងស្លាប់ គឺរៀនដើម្បីធ្វើអំពើល្អ។ ដូច្នេះឪពុកម្តាយសំខាន់ណាស់ព្រោះមានតួនាទីអប់រំកូនឲ្យបានល្អ និងធ្វើជាគម្រូល្អសម្រាប់កូនដែរ។បន្ទាប់មកគឺលោកគ្រូអ្នកគ្រូដែលត្រូវបង្ហាត់បង្រៀនក្នុងការប្រព្រឹត្តអំពីល្អឲ្យចេះប្រវត្តិសាស្ត្រ ចេះវិទ្យាសាស្ត្រ។ ពេលចប់បាក់ឌុបគឺយើងរៀនអំពីបច្ចេកទេស រៀនតាមអ្វីដែលយើងចង់រៀន ក្នុងគោលដៅកសាងសុខសន្តិភាពសម្រាប់ប្រទេសកម្ពុជាយើង និងសម្រាប់ពិភពលោកយើងទាំងមូល។

# ៥. គ្រីស្ទសាសនា ៖ គុណតម្លៃសម្រាប់សង្គមកម្ពុជានៅក្នុងសតវត្សទី ២១ ដើម្បីកសាងវិបុលភាព ក្នុងភាពចុះសម្រុងគ្នា និងសន្តិភាព(លោកអភិបាល អូលីវីយេ ម៉ីរ៉ែលម៉ារីឌ្មីតហាស្លេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជានាយកនៃវិទ្យាស្ថានសន្តប៉ូល)

**Christianity: Some Keys Values for the Cambodian Society in this 21th Century to build properity in harmony and peace?**

**Mgr Olivier Schmitthaeusler**

១.មនុស្សជាបុគ្គលមានតម្លៃថ្លៃថ្នូរ (អំណរសប្បាយ និងសេចក្តីសង្ឃឹម មហាសន្និបាតវ៉ាទីកង់ទី២-១២, ១/២៥,១)

### ១២- មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់

១.អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ ជាច្រើនមានយោបល់ស្របគ្នាអំពីចំណុចនេះថា អ្វីៗទាំងអស់នៅលើផែនដីទាំងមូលមានទិសដៅ និងអត្ថន័យដោយសារមនុស្សដែលជាស្នូលនិងជាកំពូលនៃពិភពលោក។

### ២៥-បុគ្គលម្នាក់ៗ និងសង្គមមនុស្សជំពាក់ជំពិនជាមួយគ្នា

១.មនុស្សមានលក្ខណៈជាសង្គម។ លក្ខណៈនោះបង្ហាញយ៉ាងជាក់ច្បាស់ ថាការអភិវឌ្ឍបុគ្គលម្នាក់ៗ និងការអភិវឌ្ឍសង្គមជំពាក់ជំពិនគ្នាទៅវិញទៅមក។ បុគ្គលម្នាក់ៗតាមសភាពរបស់ខ្លួនជាមនុស្សត្រូវរស់នៅក្នុងសង្គមជាតម្រូវការដ៏ចាំបាច់ ។ ប៉ុន្តែមនុស្សជា( និងត្រូវជា ) ដើមកំណើតជាប្រធាននិង ជាទិសដៅរបស់ស្ថាប័នទាំងអស់។ ការរស់នៅក្នុងសង្គមមិនមែនបន្ថែមអ្វីលើលក្ខណៈមនុស្សទេ។ មនុស្ស ចម្រើនឡើងគ្រប់វិស័យ និងអាចទៅដល់ទិសដៅកំណត់របស់ខ្លួនបាន លុះត្រាតែខ្លួនមានទំនាក់ទំនងជាមួយអ្នកដទៃជួយបម្រើគ្នាទៅវិញទៅមក និងនិយាយសន្ទនាគ្នាជាមួយមនុស្សជាបងប្អូន ។

### ២.ផលប្រយោជន៍រួម (លទ្ធិនៃគ្រិស្តសាសនាតាមព្រះសហគមន៍កាតូលិក១៩០៦-១៩០៩)

១៩០៦.ពាក្យ "ប្រយោជន៍រួម" មានន័យថា" លក្ខណៈទាំងប៉ុន្មានក្នុងសង្គមដែលហុចឲ្យទាំងពួកក្រុមផ្សេងៗ ព្រមទាំងសមាជិកនីមួយៗនៃក្រុមទាំងនោះអាចបានពេញលក្ខណៈ គ្រប់គ្រាន់ និងឆាប់ជាងមុន"(GS ២៦,១)។ ក្នុងការរស់នៅមនុស្សទាំងអស់ចាប់អារម្មណ៍នឹងផលប្រយោជន៍រួម។ មនុស្សម្នាក់ៗ ជាពិសេសអស់អ្នកកាន់អំណាចត្រូវប្រុងប្រយ័ត្នដើម្បីបានប្រយោជនរួម។ ផល

១.មនុស្សជាបុគ្គលមានតម្លៃថ្លៃថ្នូរ (អំណរសប្បាយ និងសេចក្តីសង្ឃឹម មហាសន្និបាតវ៉ាទីកង់ទី២-១២, ១/២៥,១)

## ១២- មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់

១.អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ និងអ្នកដែលផ្ញើជីវិតលើព្រះអង្គជាច្រើនមានយោបល់ស្របគ្នាអំពីចំណុចនេះថាអ្វីៗទាំងអស់នៅលើផែនដីទាំងមូល មានទិសដៅនិងអត្ថន័យដោយសារមនុស្សដែល ជាស្នូលនិងជាកំពូលនៃពិភពលោក។

## ២៥-បុគ្គលម្នាក់ៗ និងសង្គមមនុស្សជំពាក់ជំពិនជាមួយគ្នា

១. មនុស្សមានលក្ខណៈជាសង្គម។ លក្ខណៈនោះបង្ហាញយ៉ាងជាក់ច្បាស់ ថាការអភិវឌ្ឍបុគ្គលម្នាក់ៗ និងការអភិវឌ្ឍសង្គមជំពាក់ជំពិនគ្នាទៅវិញទៅមក។ បុគ្គលម្នាក់ៗតាមសភាពរបស់ខ្លួនជាមនុស្សត្រូវរស់នៅក្នុងសង្គមជាតម្រូវការដ៏ចាំបាច់ ។ ប៉ុន្តែមនុស្សជា(និងត្រូវជា) ដើមកំណើតជាប្រធាននិង ជាទិសដៅរបស់ស្ថាប័នទាំងអស់។ ការរស់នៅក្នុងសង្គមមិនមែនបន្ថែមអ្វីលើលក្ខណៈមនុស្សទេ។ មនុស្ស ចម្រើនឡើងគ្រប់វិស័យ និងអាចទៅដល់ទិសដៅកំណត់របស់ខ្លួនបាន លុះត្រាតែខ្លួនមានទំនាក់ទំនងជា មួយអ្នកដ៏ទៃជួយបម្រើគ្នាទៅវិញទៅមក និងនិយាយសន្ទនាគ្នាជាមួយមនុស្សជាបងប្អូន ។

## ២.ផលប្រយោជន៍រួម (លទ្ធិនៃគ្រិស្តសាសនាតាមព្រះសហគមន៍កាតូលិក១៩០៦-១៩០៩)

១៩០៦.ពាក្យ "ប្រយោជន៍រួម" មានន័យថា" លក្ខណៈទាំងប៉ុន្មានក្នុងសង្គមដែលហុចឲ្យទាំងពួកក្រុមផ្សេងៗ ព្រមទាំងសមាជិកនីមួយៗនៃក្រុមទាំងនោះអាចបានពេញលក្ខណៈ គ្រប់គ្រាន់ និងធូរធារ"(GS ២៦,១)។ ក្នុងការរស់នៅមនុស្សទាំងអស់ចាប់អារម្មណ៍នឹងផលប្រយោជន៍រួម។ មនុស្សម្នាក់ៗ ជាពិសេសអស់អ្នកកាន់អំណាចត្រូវប្រុងប្រយ័ត្នដើម្បីបានប្រយោជនរួម។ ផលប្រយោជន៍រួមមានលក្ខណៈចាំបាច់បីយ៉ាង៖

### ក. ការគោរពបុគ្គលម្នាក់ៗ (១៩០៧)

១៩០៧. មុនដំបូងត្រូវតែគោរពសិទ្ធបុគ្គលនីមួយៗ។ ក្នុងនាមនៃប្រយោជន៍រួម អាជ្ញាធរត្រូវតែគោរពសិទ្ធិមនុស្សជាគ្រឹះ ដែលមិនអាចលក់ដូរបានទេ។ សង្គមត្រូវឲ្យសមាជិករបស់ខ្លួនម្នាក់ៗបំពេញការ ត្រាស់ហៅខ្លួន។ ជាពិសេសប្រយោជន៍រួមស្ថិតក្នុងល័ក្ខខ័ណ្ឌគោរពសេរីភាពពីកំណើតដែលជាចាំបាច់ ដើម្បីឲ្យការត្រាស់ហៅរបស់មនុស្សរីកចម្រើន ៖ "មានសិទ្ធិធ្វើតាមមនសិកាដ៏ត្រឹមត្រូវរបស់ខ្លួន មានសិទ្ធិការពារ ជីវភាពផ្ទាល់ខ្លួន និងមានសេរីភាពត្រឹមត្រូវមានសេរីភាពខាងសាសនាជាដើម" (GS ២៦,២) ។

### ខ. សុខុមាលភាពសង្គម (១៩០៨)

១៩០៨.ទីពីរ ប្រយោជន៍រួមទាមទារឲ្យមនុស្សរស់នៅក្នុងសង្គមប្រកបដោយសុខុមាលភាព ហើយឲ្យក្រុមរបស់ខ្លួនរីកចម្រើន។ ការអភិវឌ្ឍជាសេចក្ដីសង្ខេបនៃភារកិច្ចទាំងអស់នៃសង្គម។ ក្នុងនាមប្រយោជន៍ រួមអាជ្ញាធរពិតជាត្រូវតែសម្រេចចិត្តរវាងប្រយោជនបុគ្គលផ្សេងៗ ប៉ុន្តែត្រូវរកមធ្យោបាយធ្វើយ៉ាងណាឲ្យ មនុស្សអាចឈានទៅដល់អ្វីៗដែលខ្លួនត្រូវការដើម្បីរស់នៅសមរម្យនឹងឋានៈខ្លួនជាមនុស្សដ៏ពិតប្រាកដ។ ឧទាហរណ៍៖ ឲ្យគេមានចំណីអាហារ សម្លៀកបំពាក់ផ្ទះនៅសិទ្ធិជ្រើសរើសរបៀបរស់នៅសិទ្ធិក្នុងការបង្កើតក្រុមគ្រួសារជាដើម (GS ២៦,២) ។

### គ. សុខសន្តិភាព (១៩០៩)

១៩០៩.ត្រូវឲ្យមានសន្តិភាព គឺឲ្យមានរបៀបរៀបរយដ៏ត្រឹមត្រូវយូរអង្វែង និងប្រកបដោយសុវត្ថិភាពត្រឹមត្រូវដើម្បីបានប្រយោជន៍រួម។ ដូច្នេះអាជ្ញាធរត្រូវតែធានាសន្តិសុខនៅក្នុងសង្គម និងចំពោះសមាជិក ម្នាក់ៗរបស់សង្គមនេះដោយប្រើមធ្យោបាយត្រឹមត្រូវ។ ម្យ៉ាងទៀតដោយសារប្រយោជន៍រួមម្នាក់ៗ និងទាំងអស់គ្នាមានសិទ្ធិការពារខ្លួនឯងផងដែរ ។

## ៣. មនុស្សទាំងអស់មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិទាំងអស់ក្នុងលោក (អំណរសប្បាយ និងសេចក្ដីសង្ឃឹម-មហាសន្និបាតវ៉ាទីកង់ទី ២-១២,៦៩,១)

ភោគទ្រព្យទាំងអស់ដែលមាននៅក្នុងលោកនេះ ត្រូវហូរមកដល់មនុស្សទាំងអស់តាមសេចក្ដីត្រូវការរបស់ពួកគេ និងត្រូវតាមក្បួនយុត្តិធម៌ដែលបំបែកពីសេចក្ដីស្រឡាញ់មិនបាន។ ទោះបីកម្មសិទ្ធិមានរបៀបផ្សេងៗស្របតាមការចាត់ចែងដ៏ត្រឹមត្រូវរបស់ប្រជាជាតិនីមួយៗ និងតាមកាលៈទេសៈផ្សេងៗដែលតែងតែប្រែប្រួលក្ដីក៏ត្រូវនឹកចងចាំជានិច្ចថា ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលខ្លួនបានតម្រូវឲ្យមនុស្សទាំងអស់ប្រើប្រាស់។ ហេតុនេះហើយបានជាពេលមនុស្សម្នាក់ប្រើប្រាស់ទ្រព្យសម្បត្តិ គេមិនត្រូវចាត់ទុកថាទ្រព្យសម្បត្តិ ដែលខ្លួនមានតាមច្បាប់ត្រឹមត្រូវនោះជាកម្មសិទ្ធិផ្ទាល់ខ្លួនទេតែត្រូវចាត់ទុកថាជាកម្មសិទ្ធិរួមវិញ។

ហេតុនេះមិនគ្រាន់តែខ្លួនគេទេអាចប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះបាន តែមនុស្សឯទៀតៗក៏អាចប្រើប្រាស់បានដែរ។ ម្យ៉ាងទៀតមនុស្សទាំងអស់មានសិទ្ធិនឹងបានទ្រព្យសម្បត្តិគ្រប់គ្រាន់ល្មមសម្រាប់ខ្លួនរបស់គេ និងសម្រាប់ក្រុមគ្រួសាររបស់ពួកគេដែរ។ អស់គ្រូបាធ្យាយនិងបណ្ឌិតដែលបានបង្រៀនកាលពីដើម តែងមានគំនិតដូច្នោះដែរ គឺអស់លោកតែប្រៀនប្រដៅថា គ្រីស្តបរិស័ទត្រូវជួយអ្នកក្រីក្រមិនគ្រាន់តែដោយយកអ្វីដែលគេសេសសល់ប៉ុណ្ណោះឡើយ តែដោយយកអ្វីដែលជាចាំបាច់សម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួនយកទៅចែកដល់អ្នកក្រីក្រវិញ។ រីឯអ្នកខ្វះខាតទ័លក្រវិញគេក៏មានសិទ្ធិយកទ្រព្យសម្បត្តិដ៏សម្បូររបស់គេមកទប់ទល់នឹងសេចក្ដីត្រូវការដ៏ចាំបាច់របស់ខ្លួន។ ដោយមហាសន្និបាតឃើញថា មនុស្សខ្វះអាហារបរិភោគច្រើនក្រៃលែងក្នុងពិភពលោក នោះមហាសន្និបាតសូមអំពាវនាវចំពោះមនុស្សទាំងអស់ ជាពិសេសចំពោះអ្នកកាន់អំណាចសូមនឹកដល់ពាក្យរបស់គ្រូបាធ្យាយដែលថែងថា "ចូរចែកអាហារដល់អ្នកដែលស្រេក

ឃ្លានជិតដាច់ពោះទៅ ប្រសិនបើអ្នកមិនចែកអាហារឲ្យគេបរិភោគទេ អ្នកដូចជាប្រហារជីវិតគេហើយ"។

### ៤. គោលការណ៍ជំនួស (លទ្ធិនៃគ្រិស្តសាសនាតាមព្រះសហគមន៍កាតូលិក-១៨៨៣)

តាមគោលការណ៍នេះ "សង្គមដែលមានកម្រិតខ្ពស់ មិនត្រូវធ្វើអន្តរាគមន៍ក្នុងការរស់នៅខាងក្នុងនៃសង្គមដែលមានកម្រិតទាប ដោយដកសមត្ថភាពរបស់ខ្លួនចេញបានទេ ប៉ុន្តែសង្គមដែលមានកម្រិតខ្ពស់ត្រូវតែគាំទ្រសង្គមដែលមានកម្រិតទាប ក្នុងពេលជាចាំបាច់ និងជួយសង្គមនេះឲ្យបានចាត់ចែងកិច្ចការរបស់ខ្លួនជាមួយនឹងផ្នែកផ្សេងៗដែលនៃសង្គមនេះដើម្បីផលប្រយោជន៍រួម"។ គោលការណ៍ជំនួសប្រឆាំងនឹងសមូហភាពនិយមគ្រប់បែបយ៉ាង និងបង្ហាញកំណត់ព្រំដែននៃអន្តរាគមន៍របស់រដ្ឋអំណាច។ គោលការណ៍នេះតម្រង់ទិសឲ្យទំនាក់ទំនងរវាងមនុស្ស និងសង្គមរួបរួមជាមួយគ្នាបានល្អប្រសើរ ហើយតម្រង់ទិសឲ្យការចាត់ចែងរបៀបរៀបរយជាអន្តរជាតិយ៉ាងពិតប្រាកដ។

### ៥. ការទទួលខុសត្រូវ និងការចូលរួម(អំណរសប្បាយ និងសេចក្តីសង្ឃឹមមហាសន្និបាតវ៉ាទិកង់ទី ២-៣១,១;៣)

១. ត្រូវយកចិត្តទុកដាក់អភិវឌ្ឍន៍វប្បធម៌ ដោយប្រើមធ្យោបាយដ៏ធំៗជាច្រើន ដែលមនុស្សលោកសព្វថ្ងៃមាន ដើម្បីឲ្យម្នាក់ៗអាចទទួលខុសត្រូវចំពោះខ្លួនឯង និងចំពោះក្រុមផ្សេងៗដែលខ្លួនជាសមាជិកនោះ។ ជាបឋមត្រូវចាត់ចែងការអប់រំយុវជនទោះជាមានឋានៈវណ្ណៈណាក្តីក្នុងសង្គមដើម្បីឲ្យអាចបង្កើតជនជាន មនុស្សទាំងប្រុសទាំងស្រីមិនគ្រាន់តែឲ្យគេមានចំណេះដឹងច្រើនប៉ុណ្ណោះទេ តែគេអាចមានបុគ្គលិកលក្ខណៈរឹងប៉ឹងជ្បិតសម័យឥឡូវ ត្រូវការមនុស្សបែបនេះយ៉ាងខ្លាំងជាងគេ ។

២. ហេតុនេះត្រូវដាស់តឿនមនុស្សទាំងអស់ឲ្យមានបំណងចង់រួមចំណែកក្នុងកិច្ចការរួម។ ត្រូវសរសើរប្រជាជាតិខ្លះដែលនាំប្រជាពលរដ្ឋជាច្រើនឲ្យរួមចំណែកក្នុងកិច្ចការរដ្ឋ ដោយមានសេរីភាពយ៉ាងពិតប្រាកដ។ ក៏ប៉ុន្តែត្រូវនឹកដល់សភាពការណ៍ប្រជាជននីមួយៗ និងនឹកគិតថារដ្ឋអំណាចក៏ត្រូវការកាន់អំណាចយ៉ាងរឹងមាំដែរ។ ត្រូវឲ្យប្រជាពលរដ្ឋទាំងអស់យល់ថាក្រុមទាំងប៉ុន្មានក្នុងសង្គម កាន់តែមានឧត្តមគតិដែលទាក់ទាញចិត្តគេ គឺឲ្យបម្រើប្រជាពលរដ្ឋដូចគ្នា ទើបប្រជាពលរដ្ឋទាំងអស់មានបំណងចង់រួមចំណែកក្នុងការរស់នៅរបស់ក្រុមទាំងនោះ។ គួរឲ្យនឹកយ៉ាងត្រឹមត្រូវថា អនាគតអាស្រ័យលើអស់អ្នកដែលផ្តល់ឲ្យមនុស្សតំណក្រោយៗ ឲ្យគេមានមូលហេតុចង់រស់តទៅទៀត និងមានសេចក្តីសង្ឃឹម។

### ៦. សាមគ្គីភាពរបស់មនុស្ស (លទ្ធិនៃគ្រិស្តសាសនាតាមព្រះសហគមន៍កាតូលិក ១៩៤០-១៩៤១)

១៩៤០.ជាដំបូងមនុស្សរួមសាមគ្គីនឹងគ្នា ក្នុងការចែកទ្រព្យសម្បត្តិ និងការផ្តល់ប្រាក់បៀវត្សនៃការងារ។ ម្យ៉ាងទៀតដោយសារគេរួមសាមគ្គីនឹងគ្នា មនុស្សត្រូវតែខិតខំពង្រឹងរបៀបរៀបរយក្នុងសង្គម ឲ្យកាន់តែប្រកបដោយយុត្តិធម៌ ដែលនឹងកាត់បន្ថយភាពតានតឹង និងដែលជាភាពងាយស្រួលក្នុងការដោះស្រាយទំនាស់។

១៩៤១.មានតែនៅពេលដែលមនុស្សរួមសាមគ្គីនឹងគ្នាគ្រប់បែបយ៉ាង ទើបអាចដោះស្រាយបញ្ហា ក្នុងសង្គម និងខាងសេដ្ឋកិច្ចគឺឲ្យជនក្រីក្ររួមសាមគ្គីរវាងគ្នានឹងគ្នា ឲ្យអ្នកមាននិងអ្នកក្រួបរួមគ្នា ឲ្យកម្មកររួមជាមួយគ្នាឲ្យថៅកែនឹងបុគ្គលិកក្នុងសហគ្រាសរួមសាមគ្គីគ្នា ឲ្យមានសាមគ្គីភាពរវាងប្រជាជាតិនិងប្រជាជននានា។ របៀបរៀបរយខាងសីលធម៌ ទាមទារឲ្យមានសាមគ្គីភាពអន្តរជាតិ។ សន្តិភាពក្នុងពិភពលោកពឹងផ្អែកលើសាមគ្គីភាពនេះម្យ៉ាងដែរ។

### ៧. ត្រូវជ្រើសរើសយកប្រយោជន៍អ្នកក្រីក្រ មុនរកប្រយោជន៍អ្នកឯទៀតទាំងអស់ (សម្តេចប៉ាប ហ្វ្រង់ស៊ិស្វ, អំណរសប្បាយដែលហូរមកពីដំណឹងល្អ)

១៨៧. ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទម្នាក់ៗ និងត្រាស់ហៅសហគមន៍នីមួយៗឲ្យទៅជាគ្រឿងឧបករណ៍របស់ព្រះអង្គដើម្បីរំដោះ និងលើកស្ទួយជនក្រីក្រ។ ធ្វើដូច្នេះអ្នកក្រីក្រអាចចូលរួមយ៉ាងពេញលេញក្នុងសង្គមបាន។ យើងត្រូវតែយកចិត្តទុកដាក់ស្តាប់ សូរសម្រែករបស់ជនក្រីក្រហើយសង្គ្រោះគេទៀតផង។

### ៨.ភាតរភាពជាមូលដ្ឋានគ្រឹះ និងជាផ្លូវនាំមកនូវសន្តិភាព ( សារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ិស្វ នៃទិវាសន្តិភាព ខែមករា ឆ្នាំ ២០១៤)

- ភាតរភាពជាមូលដ្ឋានគ្រឹះ និងជាផ្លូវនាំមកនូវសន្តិភាព
- ភាតរភាពជាលក្ខខណ្ឌដំបូងប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ
- ការស្វែងយល់ភាតរភាពនៅក្នុងសេដ្ឋកិច្ច
- ភាតរភាពពន្លត់សង្គ្រាម
- អំពើពុករលួយ និង គម្រោងឧក្រិដ្ឋកម្មគំរាមកំហែងដល់ភាតរភាព
- ភាតរភាពជួយការពារ និងរក្សាធម្មជាតិ។

### សរុបសេចក្តី

យើងដឹងហើយថា ព្រះបិតានឹងសួរយើងម្នាក់ៗថា "តើអ្នកបានប្រព្រឹត្តយ៉ាងណាចំពោះបងប្អូន?" (កណ ៤,៩-១០)។មនុស្សជាច្រើនក្នុងសកលលោក មិនអើពើនឹងជួយមនុស្សសោះ។ដូច្នេះគេបណ្តាលឲ្យការរស់នៅរបស់បងប្អូនជាច្រើនអនេកត្រូវវេទនា។ ហេតុនេះយើងត្រូវតែណែនាំមនុស្សកាន់តែច្រើនឲ្យរួមសាមគ្គីគ្នា និងសម្តែងភាតរភាពវិញ ដែលអាចផ្តល់ឲ្យបងប្អូនទាំងនោះមានសេចក្តីសង្ឃឹមឡើងវិញ អាចមានសេចក្តីក្លាហានឡើងវិញ អាចធ្វើដំណើរតាមផ្លូវនាសម័យឥឡូវ ទោះបីគេត្រូវជួបបញ្ហាជាច្រើនក្តី ឲ្យគេមានទីដៅថ្មីតាមផ្លូវនោះ ដែលព្រះបិតាប្រគល់នៅក្នុងដៃរបស់យើង ។

ព្រះសហគមន៍កាតូលិក សូមបកស្រាយពន្យល់ថា៖

- មនុស្សជាបុគ្គលមានតម្លៃដ៏ថ្លៃថ្នូរមនុស្សជារូបតំណាងរបស់ព្រះ និងបុគ្គលម្នាក់ៗឬក៏សង្គមមនុស្ស

ជំពាក់ជំពិនជាមួយគ្នា។

- ផលប្រយោជន៍រួម គឺការធ្វើអ្វីៗដោយគិតទៅដល់មនុស្សទាំងអស់គ្នាដែលរស់នៅលើលោកនេះ។ ហើយផលប្រយោជន៍រួមមានលក្ខណៈចាំបាច់បីយ៉ាងមាន៖
  + ការគោរពបុគ្គលម្នាក់ៗ
  + សុខុមាលភាពសង្គម
  + សុខសន្តិភាព។
- មនុស្សទាំងគ្នាមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិទាំងអស់ក្នុងលោក គឺមនុស្សម្នាក់ៗអាចប្រើប្រាស់ទ្រព្យសម្បត្តិ ឬក៏អ្វីៗដែលមាននៅលើលោកនេះបាន ប៉ុន្តែត្រូវរកដោយយុត្តិធម៌។
- គោលការណ៍ជំនួស គឺជាគោលការណាន៍មួយដែលបង្កើតឡើងជួសជុលឬជំនួសគោលការណ៍មុន។
- ការទទួលខុសត្រូវនិងការចូលរួម គឺការទទួលនូវអ្វីដែលយើងធ្វើនិងប្រព្រឹត្ត។ ការចូលរួមគឺការផ្តល់សិទ្ធិឲ្យពួកគេចូលរួមបញ្ចេញមតិ នៅក្នុងការអភិវឌ្ឍប្រទេស ហើយដោយមិនមានការរើសអើង។
- សាមគ្គីរបស់មនុស្ស គឺជាការរួបរួមគ្នាជាកម្លាំងដើម្បីសម្រេចគោលដៅរួម។
- ត្រូវជ្រើសរើសប្រយោជន៍អ្នកក្រីក្រ មុនពេលរកប្រយោជន៍របស់អ្នកឯទៀតទាំងអស់ គឺយើងត្រូវគិតឬមើលពីផលប្រយោជន៍របស់ជនក្រីក្រជាមុន ហើយទើបយើងទៅជួយអ្នកដទៃទៀត។
- ភាតរភាពជាមូលដ្ឋានគ្រឹះ និងជាផ្លូវនាំមកនូវសន្តិភាព
- ភាតរភាពជាលក្ខខណ្ឌដំបូងប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ
- ការស្វែងយល់ពីភាតរភាពនៅក្នុងសេដ្ឋកិច្ច
- ភាតរភាពពន្លត់សង្គ្រាម
- អំពើពុករលួយ និងគម្រោងឧក្រឹតកម្មគំរាមគំហែងដល់ភាតរភាព
- ភាតរភាពជួយការពារ និងរក្សាធម្មជាតិ។

# ៤. គ្រីស្ទសាសនា ៖ គុណតម្លៃសម្រាប់សង្គមកម្ពុជានៅក្នុង សតវត្សទី ២១ ដើម្បីកសាងវិបុលភាព ក្នុងភាពចុះសម្រុងគ្នា និង សន្តិភាព(លោកអភិបាល អូលីវីយេ មីឆែលម៉ារីឆ្មិតហាស្លេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជានាយកនៃវិទ្យាស្ថានសន្តប៉ូល)

# Christianity: Some Keys Values for the Cambodian Society in this 21th Century to build properity in harmony and peace?

**Mgr Olivier Schmitthaeusler**

## 1. Human Being : *(GAUDIUM ET SPES 12,1,3-5/25,1)*

**12.1** According to the almost unanimous opinion of believers and unbelievers alike, all things on earth should be related to man as their center and crown.

**12.3** For Sacred Scripture teaches that man was created "to the image of God," is capable of knowing and loving his Creator, and was appointed by Him as master of all earthly creatures(1) that he might subdue them and use them to God's glory.(2) "What is man that you should care for him? You have made him little less than the angels, and crowned him with glory and honor. Youhave given him rule over the works of your hands, putting all things under his feet" (Ps. 8:5-7).

**12.4** But God did not create man as a solitary, for from the beginning "male and female he created them" (Gen. 1:27). Their companionship produces the pri mary form of interpersonal communion. For by his innermost nature man is a social being, and unless he relates himself to others he can neither live nor develop his potential.

**12.5** Therefore, as we read elsewhere in Holy Scripture God saw "all that he had made, and it was very good" (Gen. 1:31).

**25.1** Man's social nature makes it evident that the progress of the human person and the advance of society itself hinge on one another. For the beginning, the subject and the goal of all social institutions is and must be the human person which for its part and by its very nature stands completely in need

of social life.(3) Since this social life is not something added on to man, through his dealings with others, through reciprocal duties, and through fraternal dialogue he develops all his gifts and is able to rise to his destiny.

## 2. The common good *(Catechism of the Catholic Church, cc.1906-1909)*

**1906.** By common good is to be understood "the sum total of social conditions which allow people, either as groups or as individuals, to reach their fulfillment more fully and more easily."26 The common good concerns the life of all. It calls for prudence from each, and even more from those who exercise the office of authority. It consists of three essential elements:

### - Respect for the individual – *(cc.1907)*

**1907.** First, the common good presupposes respect for the person as such. In the name of the common good, public authorities are bound to respect the fundamental and inalienable rights of the human person. Society should permit each of its members to fulfill his vocation. In particular, the common good resides in the conditions for the exercise of the natural freedoms indispensable for the development of the human vocation, such as "the right to act according to a sound norm of conscience and to safeguard . . . privacy, and rightful freedom also in matters of religion."27

### - Welfare-social – *(cc.1908)*

**1908.** Second, the common good requires the social well-being and development of the group itself. Development is the epitome of all social duties. Certainly, it is the proper function of authority to arbitrate, in the name of the common good, between various particular interests; but it should make accessible to each what is needed to lead a truly human life: food, clothing, health, work, education and culture, suitable information, the right to establish a family, and so on.

**- Peace –** ***(cc.1909)***

**1909.** Finally, the common good requires peace, that is, the stability and security of a just order. It presupposes that authority should ensure by morally acceptable means the security of society and its members. It is the basis of the right to legitimate personal and collective defense.

**3. The universal destination of goods –** ***(GAUDIUM ET SPES 69,1)***

Under the leadership of justice and in the company of charity, created goods should be in abundance for all in like manner.(8) Whatever the forms of property may be, as adapted to the legitimate institutions of peoples, according to diverse and changeable circumstances, attention must always be paid to this universal destination of earthly goods. In using them, therefore, man should regard the external things that he legitimately possesses not only as his own but also as common in the sense that they should be able to benefit not only him but also others.(9) On the other hand, the right of having a share of earthly goods sufficient for oneself and one's family belongs to everyone.

If one is in extreme necessity, he has the right to procure for himself what he needs out of the riches of others

Since there are so many people prostrate with hunger in the world, this sacred council urges all, both individuals and governments, to remember the aphorism of the Fathers, "Feed the man dying of hunger, because if you have not fed him, you have killed him,"

**4. Subsidiary – (Catechism of the Catholic Church, cc.1883)**

**1883.** The teaching of the Church has elaborated the principle of subsidiarity, according to which "a community of a higher order should not interfere in the internal life of a community of a lower order, depriving the latter of its functions, \ but rather should support it in case of need and help to co- ordinate its activity with the activities of the rest of society, always with a view to the common good."

5. **Responsibility and participation – (GAUDIUM ET SPES 31,1;3)**

**31.1** In order for individual men to discharge with greater exactness the obligations of their conscience toward themselves and the various group to which they belong, they must be carefully educated to a higher degree of culture through the use of the immense resources available today to the human race. Above all the education of youth from every social background has to be undertaken, so that there can be produced not only men and women of refined talents, but those great-souled persons who are so desperately required by our times.

**31.3** Hence, the will to play one's role in common endeavors should be everywhere encouraged. Praise is due to those national procedures which allow the largest possible number of citizens to participate in public affairs with genuine freedom. Account must be taken, to be sure, of the actual conditions of each people and the decisiveness required by public authority. If every citizen is to feel inclined to take part in the activities of the various groups which make up the social body, these must offer advantages which will attract members and dispose them to serve others. We can justly consider that the future of humanity lies in the hands of those who are strong enough to provide coming generations with reasons for living and hoping.

6. **Solidarity – *(Catechism of the Catholic Church, cc.1940-1941)***

**1940.** Solidarity is manifested in the first place by the distribution of goods and remuneration for work. It also presupposes the effort for a more just social order where tensions are better able to be reduced and conflicts more readily settled by negotiation.

**1941.** Socio-economic problems can be resolved only with the help of all the forms of solidarity: solidarity of the poor among themselves, between rich and poor, of workers among themselves, between employers and employees in a business, solidarity among nations and peoples. International solidarity is a requirement of the moral order; world peace depends in part upon this.

7. **The preferential option for the poor –** ***(Pope Francis, Evangelli Gaudium)***

**187.** Each individual Christian and every community is called to be an instrument of God for the liberation and promotion of the poor, and for enabling them to be fully a part of society. This demands that we be docile and attentive to the cry of the poor and to come to their aid.

8. **FRATERNITY, THE FOUNDATION AND PATHWAY TO PEACE (Pope Francis, Message for the Peace Day, January 2014)**

a. Fraternity, the foundation and pathway to peace
b. Fraternity, a prerequisite for fighting poverty
c. The rediscovery of fraternity in the economy
d. Fraternity extinguishes war
e. Corruption and organized crime threaten fraternity
f. Fraternity helps to preserve and cultivate nature

## CONCLUSION

We know that God will ask each of us: What did you do for your brother? (cf. Gen 4:9-10). The globalization of indifference, which today burdens the lives of so many of our brothers and sisters, requires all of us to forge a new worldwide solidarity and fraternity capable of giving them new hope and helping them to advance with courage amid the problems of our time and the new horizons which they disclose and which God places in our hands. (Pope Francis, Message for Peace, 1st January 2015)

# ៦. ទស្សនវិស័យ និងផែនការសកម្មភាពដើម្បីក្លាយជាតួរអង្គអភិវឌ្ឍនៃសង្គមកម្ពុជា (លោក សន ជ័យ ប្រធានបណ្ដាញគណនេយ្យភាពសង្គម )

**Perspectives and Action Plan to Social development Actor in Cambodia**
**20 May, 2015**
**Saint Paul Institute, Takeo**
**Presented by SAN Chey, ANSA-EAP**
**Perspectives and Action Plan to Social development Actor in Cambodia**

### ABOUT ANSA-EAP

- Regional network ( Foundation ) registered in 2011
- Promote citizen monitoring of Government performance to foster quality of public service for better social welfare and people's rights
- Putting Social Accountability in practice
- Anti-Corruption

### CURRENT PROJECTS

- Checkmyschool- regional initiative working with KIND Cambodia, TI Indonesia, DEMO Mongolia
- CPA Citizen Participatory Audit- Philippines
- Capacity Building-Partner
- Social Accountability Institute-Regional
- Training service-Regional
- Education Monitoring- Cambodia
- Public service monitoring-Anti-Corruption

### CAMBODIAN PROFILE

- Cambodia is one of the developing countries in ASEAN with poverty line at 38%.
- Population of 14 million and foreigners in both legal and illegal status
- Three separation powers of judiciary, legislature and Govt. Prime minister is the chief of executing body.
- There are two main administrations of national and ( Provincial and Communal level ) sub national administration.
- Public procurement law, anti-corruption law,

- High rank of corruption
- Absence of access to information law
- Draft cyber law and NGO law
- Bribery in public service delivery
- Failure to monitor public service delivery lead to poor quality and poor social welfare
- Around 63% of population are youth
- National Policy for youth development

**YOUTH CHALLENGES**

- Limit access to education service and drop out
- Youth policy is not proper  enforced
- Migration , local and international
- Poor leadership and life skill
- Limited involvement in politics-decision making
- Challenges for higher education for poor students
- Low capacity in using foreign language- ASEAN Economic Community
- Alcohol and drug

**STATUS OF CSO IN CAMBODIA**

- Right to association mention in the constitutional law of Kingdom of Cambodia
- Legal NGO required to register at the Ministry of Interior
- Nearly 4000 NGOs were registered but only around 1000 are in good operation in sectors education, health, NRM.
- 4 kinds of NGOs are seen, independent, pro-Govt, pro-opposition party and informal group
- Partnership between CSO and Government are still mentioned in the political plat-form
- Remaining sensitivity and controversial between NGOs and Govt

**STRENGTH AND CONTRIBUTION TO SOCIAL ECONOMIC DEVELOPMENT AND GOVERNANCE**

- Organized community for better family economy
- NGO alliance, Coalition and individual NGOs
- Some initiatives appreciates by Govt
- Continue work even refusal or threaten by the Govt
- Area of NGO work in Human rights, good governance, Social Accountability, anti-corruption, policy monitoring, community development and social services and services.
- Some NGOs transforms as the private sector  such as becoming private

university and banks
- Coalition building for key issue- ASEAN, Report to UN
- Regional coordination group for specific project and cases

**PERCEPTION BY GOVT AND PRIVATE SECTOR TO CSO**
- Supporting Government program and partnership in being a part of Govt plan
- Support opposition party for right group- land right, environment and NRM, democracy ( election monitoring ), policy monitoring and anti-corruption
- Constructive engagement in good governance and Social Accountability
- Private sector looks reluctant to cooperate with and support NGOs, especially the advocacy group

**MAJOR CHALLENGES**
- Shortage of Access to information in budgeting, development program
- Narrow space for engagement and monitoring Govt program
- Draft NGO Law
- Draft Cyber law
- Political stability and Corruption
- NGO dependency on fund from donors
- Limit NGO professional

**FUTURE OUTLOOK FOR YOUTH**
- Provision of leadership and innovation
- Vocational training and English course for rural youth
- Engaging youth to politics for better decision making
- Opportunity for youth exchange
- Internship opportunity
- Advocate to a proper enforcement of Youth policy
- Support and provide specific skill development
- Youth sustaining income generation from Govt and CSO
- Youth movement to hold Govt more accountable and responsive

**CSO**

- NGO sustainability in both income generation and fund from donors
- Promote the role of CSO as the constructive engagement and evidence based advocacy
- Strengthening the more independent role of CSO and capacity in monitoring Govt build more stronger network
- Joint intervention to postpone draft NGO law and cyber law
- Strengthen more collaboration between national to regional group and global level to influence Govt on the cases of local and cross countries.
- Exchange good practice and experience
- Engage Govt for more public accountability and transparency.

**RECOMMENDATION**

- Govt, CSO and private sector work together for youth
- Set up the vocational training center for drop out group
- Local labor market plan
- Social land concession for youth and resource allocation to run business
- Build a capable  and organized youth group
- Promotion of local product and urban market access

## II. សិក្ខាសាលារដើម្បីសំយោគសិក្ខាសាលា និងពិភាក្សាក្រុម Workshops

### ក. តម្លៃ និងសេចក្ដីថ្លៃថ្នូរសម្រាប់ទាំងអស់គ្នា

យោងតាមទស្សនវិទូ ប៉ូល រីកឺរ ( Paul Ricoeur ) គោលគំនិតនៃសេចក្ដីថ្លៃថ្នូរសំដៅចំពោះគំនិតដែលថា "អ្វីៗគឺ បណ្ដាលមកពីមនុស្ស ដោយហេតុតែមានសភាវជាមនុស្ស"។

តាមការពិតឫសគល់នៃពាក្យ Dignitas សំដៅដល់អ្វីដែលថ្លៃថ្នូរ គុណធម៌ កិត្តិយស ការពិចារណា ការរាប់អាន។ ហើយជួនកាលពាក្យ Dignitas ធ្វើឲ្យយើងគិតដល់ការគោរពដែលមនុស្សម្នាក់ៗសមនឹងទទួលបាន និងជួនកាលសំដៅទៅដល់សេចក្ដីគោរពចំពោះខ្លួនឯងវិញ ។

ជាតុពិតទៅលើភាពថ្លៃថ្នូរ គឺជាគុណសម្បត្តិមួយ ពីព្រោះវាអះអាងពីមនុស្ស អះអាងពីធនធាន និងគុណសម្បត្តិសជ្ឈន្តិកៈ និងជាកម្លាំងនៃគំនិតដែលធ្វើឲ្យមនុស្សក្លាយទៅជាគុណសម្បត្តិមួយដែលត្រូវគោរព និងជាគុណសម្បត្តិឯកឯងមួយដែលត្រូវការពារ ។

កិត្តិយសនៃសេចក្ដីថ្លៃថ្នូរ គឺជាកត្តាមួយដែលសំខាន់បំផុតសម្រាប់ទាំងអស់គ្នា ។ ហើយតម្លៃថ្លៃថ្នូរគឺកើតចេញពីការទំនាក់ទំនង គ្នារវាងបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដោយរាក់ទាក់ និងពីសង្គមមួយទៅសង្គមទៀត ។

### ខ.ផលប្រយោជន៍រួម

ផលប្រយោជន៍ជាកត្តាដែលចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍសង្គម និងប្រទេសជាតិទាំងមូល ។ ពីព្រោះមនុស្សម្នាក់ៗ មិនអាចរស់នៅម្នាក់ឯងបានឡើយ ។ ទ្រព្យសម្បត្តិសមូហភាព/ផលប្រយោជន៍រួមនេះបានទទួលឡើងវិញនូវតួនាទីដ៏សំខាន់បំផុតនៅក្នុងការពិចារណា ស្ដីពីអធិបតេយ្យភាពប្រជាជន និងស្ដីពីអភិបាលកិច្ចប្រជាធិបតេយ្យ ។ សញ្ញាណនេះត្រូវបានគេលើកឡើងយ៉ាងខ្លាំងនៅក្នុងកម្រិតផ្សេងៗ នៅក្នុងកិច្ចពិភាក្សារបស់អ្នកឯកទេសមុខវិជ្ជាសេដ្ឋកិច្ច អ្នកច្បាប់ និងទស្សនវិទូ ដែលមើលឃើញពីភាពចាំបាច់ក្នុងការស្វែងរកឲ្យឃើញនូវគោលគំនិតមួយដែលអាចនឹងតំណាងឲ្យការកែប្រែគំរូ នៅក្នុងការកំណត់គោលនយោបាយនានាសម្រាប់ការអភិវឌ្ឍ ដោយបរិយាប័ណ្ណមួយ ។ ហើយយើងម្នាក់ៗចូលរួមក្នុងសង្គមយ៉ាងសំខាន់ ដោយបុគ្គលម្នាក់ៗចេះ និងមានការទទួលខុសត្រូវខ្ពស់ មានស្មារតី កម្លាំងប្រាជ្ញាបញ្ចូលសកម្មភាពទាំងអស់នៃផលប្រយោជន៍រួម ។

### គ.ការប្រឈមមុខរបស់ប្រទេសកម្ពុជានៅក្នុងប្រទេស

ការប្រឈមមុខរបស់ប្រទេសកម្ពុជានៅក្នុងប្រទេស គឺមានការប្រឈមមុខខ្លាំងជាមួយនឹងបរិបទសេដ្ឋកិច្ច និងសង្គម ។ យុវជនប្រមាណជាជាង ៣០០,០០០ នាក់ជារៀងរាល់ឆ្នាំ បានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ និងស្វែងរកការងារធ្វើជារៀងរាល់ឆ្នាំ ។ បញ្ហាប្រឈម និងឱកាសដែលយុវជនជួបប្រទះបច្ចុប្បន្ននៅប្រទេសកម្ពុជា គឺត្រូវបានមើលឃើញក្នុងបរិបទនៃកំណើតសេដ្ឋកិច្ច ដែលកំពុងកាត់បន្ថយភាពក្រីក្រ

និងកំពុងបង្កើតនូវវិសមភាព។ ការធ្វើចំណាកស្រុករបស់ប្រជាជន ពីជនបទទៅកាន់ទីក្រុង គឺនឹងកំពុងបានជះឥទ្ធិពលយ៉ាងខ្លាំងសម្រាប់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសង្គមកម្ពុជា និងយុវជនរបស់ខ្លួន ។

បញ្ហាចំបងមួយដែលជះឥទ្ធិពលទៅដល់យុវជនកម្ពុជាគឺបញ្ហាការងារ។ កម្លាំងពលកម្មគឺកំពុងកើនឡើងយ៉ាងឆាប់រហ័សប្រមាណជាង ៣០០,០០០ នាក់ (បីសែននាក់)ក្នុងមួយឆ្នាំ ហើយវានឹងអាចកើនឡើងរហូតដល់ជាង ៤០០, ០០០ (បួនសែន)នាពេលអនាគត។ ភាពមិនឆ្លើយតបចំពោះទិន្នផល និងចំណាយ ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធនិងទីផ្សារ។ អ្វីដែលត្រូវខិតខំបន្ថែមទៀតនោះ គឺត្រូវជំរុញឲ្យមានច្រើននូវសហគ្រាសខ្នាតតូច និងមធ្យមព្រមទាំងការវិនិយោគផ្នែកកសិពាណិជ្ជកម្ម តាមរយៈការទាក់ទាញវិនិយោគទុនបរទេសក្នុងវិស័យកសិពាណិជ្ជកម្ម ព្រមទាំងពង្រឹងផ្នែកបរិស្ថាន។ ក្នុងនោះដែរអាត្រាអនក្ខរភាពបានជះឥទ្ធិពលដល់យុវជនប្រទេសកម្ពុជាប្រសិនបើអ្នកជាអ្នកអភិវឌ្ឍប្រទេសកម្ពុជាសូមជ្រើសរើសគំនិតបីដើម្បីអភិវឌ្ឍដោយជោគជ័យ។ ចូរពន្យល់ចំណុចនីមួយៗឲ្យបានក្បោះក្បាយ។

គំនិតក្នុងការបកស្រាយតាមរយៈការបកស្រាយពីក្រុមនីមួយៗ គឺ

- ការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ដោយធ្វើទៅលើគុណភាពជំនាញ ភាសា ការអប់រំមនុស្ស និងប្រព័ន្ធផ្សព្វផ្សាយ
- ពង្រឹងការអប់រំពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ខ្ពស់
- បំណិនជីវិត ក្រមសីលធម៌
- បង្កើតគំនិតច្នៃប្រឌិត។
- ការអភិវឌ្ឍធនធានមនុស្ស
- កត្តាអប់រំ
- កត្តាសង្គម
- កត្តាខ្លួនឯង
- កត្តាគ្រួសារ។
- ពង្រឹងប្រសិទ្ធិភាពប្រព័ន្ធសេដ្ឋកិច្ច ដោយធ្វើការបង្កើតជាសហគ្រាសខ្នាតតូច និងខ្នាតមធ្យម។
- ពង្រឹងប្រព័ន្ធនយោបាយ ដោយគោរពទៅតាមបទបញ្ញត្តិរបស់សង្គម
- កសាង និងវិសោធនកម្មច្បាប់ដែលចាំបាច់
- ធ្វើឲ្យច្បាប់មានតម្លៃជាសកល
- គោរពទស្សនៈនយោបាយ (គោរពមតិ)
- គោរពនយោបាយច្បាស់លាស់ លទ្ធិប្រជាធិបតេយ្យ។
- អភិវឌ្ឍវិស័យទីផ្សារសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ៖
- បង្កើតការងារជូនប្រជាពលរដ្ឋ
- បង្កើតប្រព័ន្ធជារាសាស្ត្រ សម្រាប់អភិវឌ្ឍវិស័យកសិកម្ម

- បង្កើតផលិតផលក្នុងស្រុក
- ទាក់ទាញវិនិយោគទុនបរទេសមកដាក់ទុនក្នុងស្រុករបស់យើង។
- ពង្រឹងវិស័យបច្ចេកទេស ដោយបណ្តុះបណ្តាលវគ្គខ្លីនៃជំនាញវិជ្ជាជីវៈ
- វិស័យច្បាប់ (យុត្តិធម៌សង្គម)
- ពង្រឹងការអនុវត្តច្បាប់ឲ្យបានច្បាស់លាស់
- ការផ្សព្វផ្សាយអំពីច្បាប់ឲ្យបានច្បាស់លាស់ និងបំបាត់អំពើពុករលួយ។
- ពង្រឹងវិស័យសុខាភិបាល គឺព្យាយាមជំរុញ និងបណ្តុះបណ្តាលអំពីវិជ្ជាជីវៈផ្នែកសុខាភិបាលឲ្យបានច្បាស់លាស់ពង្រឹងផ្នែកសីលធម៌ក្នុងការទទួលអ្នកជំងឺ និងផ្តល់សេវាកម្មដ៏ទុកចិត្តក្នុងការថែទាំអ្នកជំងឺ
- ពង្រឹងនូវវប្បធម៌របស់ខ្មែរឲ្យបានរឹងមាំ សិល្បៈ សិប្បកម្ម តម្បាញសូត្រ
- ទំនាក់ទំនងល្អជាមួយប្រទេសជិតខាង
- ពង្រឹងការថែរក្សាបរិស្ថានធម្មជាតិ ដូចជាទឹក បឹង ស្ទឹង ព្រៃឈើឲ្យបានគង់វង្ស និងផ្សព្វផ្សាយឲ្យមានការដាំឡើងវិញ
- ពង្រឹងច្បាប់ចរាចរណ៍ផ្លូវគោក

ការអភិវឌ្ឍប្រទេសជាតិជាកត្តាសំខាន់ សម្រាប់ប្រជាពលរដ្ឋដែលត្រូវតែចូលរួមយ៉ាងសកម្ម ទាំងស្មារតីប្រាជ្ញា ដោយស្វែងយល់ពីផលប្រយោជន៍រួម និងការទទួលខុសត្រូវខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន។

## III. សរុបសេចក្តី Final Statement

### យើងជាអ្នកចូលរួម ...យើងជឿថា...គោលការណ៍

យើងខ្ញុំទាំងអស់គ្នាដែលជាសិក្ខាកាមចំនួន១៦៥ នាក់ ដែលជានិស្សិត បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថាន សន្តប៉ូល នាយកវិទ្យាល័យទាំង១២ ក្នុងខេត្តតាកែវ តំណាងអង្គការសង្គមស៊ីវិល តំណាងការិយាល័យព្រះសហគមន៍កាតូលិក សាស្ត្រាចារ្យតំណាងសាកលវិទ្យាល័យ ប៉ីហ្គាម៉ូ រួមជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់លោកអភិបាល អូលីវីយេ មីឆែល ម៉ារីផ្មិតហស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជានាយកវិទ្យាស្ថានសន្តប៉ូល ។

យើងខ្ញុំទាំងអស់គ្នា បានចូលរួមសិក្ខាសាលាស្រាវជ្រាវស្តីអំពី "គុណតម្លៃដើម្បីកសាងសង្គមកម្ពុជានៅសតវត្សទី២១ " ចាប់ពីថ្ងៃទី១៨ ដល់ ២០ ខែឧសភា ឆ្នាំ២០១៥ ដែលរៀបចំដោយវិទ្យាស្ថាន សន្តប៉ូល ក្រោមការសហការជាមួយអង្គការយូណេស្កូ ផ្នែកសិទ្ធិមនុស្ស និងសាកលវិទ្យាល័យប៉ីហ្គាម៉ូ នៃប្រទេសអ៊ីតាលី ។

សិក្ខាកាមទាំងអស់ដែលបានចូលរួមយល់ឃើញថា "មនុស្សមានតម្លៃនិងសេចក្តីថ្លៃថ្នូរស្មើៗគ្នាដែលមិនអាចកាត់ថ្លៃបាន ហើយមនុស្សជាស្នូលនៃគុណតម្លៃក្នុងគ្រប់ការសម្រេចចិត្តទាំងអស់ដែលនាំឲ្យរកឃើញនូវផលប្រយោជន៍រួមតាមរយៈការគោរពសិទ្ធិ តម្លៃ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ប្រកបដោយការទទួលខុសត្រូវ និងការចូលរួមជួយគ្នាទៅវិញទៅមកយ៉ាងសកម្មក្នុងសាមគ្គីភាព និងភាតរភាព..." ។

យោងតាមអត្ថន័យខាងលើនេះ ក្នុងបរិបទដើម្បីចូលរួមចំណែកកសាងអភិវឌ្ឍសង្គមកម្ពុជានិងសហគមន៍អាស៊ីអាគ្នេយ៍(អាស៊ាន) ដែលនឹងធ្វើសមាហរណកម្មសេដ្ឋកិច្ចវប្បធម៌រួមគ្នានៅសតវត្សទី២១ នេះយើងសូមផ្តល់គោលការណ៍សំខាន់ៗសម្រាប់ចូលរួមអភិវឌ្ឍប្រទេសកម្ពុជា និងអាស៊ានដែលមានដូចជា៖

គោលការណ៍សម្រាប់ចូលរួមអភិវឌ្ឍប្រទេសកម្ពុជា៖

- ពង្រឹងលើការចូលរួមវេទិកាសាធារណៈ
- លើកកម្ពស់សិទ្ធិទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា
- លើកកម្ពស់សមត្ថភាពដល់អ្នកមានគំនិតច្នៃប្រឌិតថ្មី និងជំនាញ
- រៀបចំរចនាសម្ព័ន្ធ និងភាពជាដៃគូជាមួយប្រទេសជិតខាង
- បង្កើតប្រព័ន្ធផ្សព្វផ្សាយសង្គម និងគោលនយោបាយអប់រំល្អ
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- អនុវត្តគោលនយោបាយសហវិមជ្ឈការ
- Self Development កម្មវិធីអភិវឌ្ឍផ្ទាល់ខ្លួន

ជំរុញឪពុកម្តាយឲ្យបញ្ជូនកូនទៅសាលារៀន
កំណែទម្រង់ប្រព័ន្ធអប់រំ ឲ្យស៊ីជម្រៅ
ពង្រឹងកម្មវិធីអន្តរសាសនា
ពង្រឹងភាពជាអ្នកដឹកនាំលើគ្រប់វិស័យ
បំបាត់អំពើពុករលួយ
ពង្រឹងប្រព័ន្ធសុខាភិបាលក្នុងប្រទេស និងគ្រប់មូលដ្ឋាន
គិតពីប្រយោជន៍រួម និងមានសេរីភាពបញ្ចេញមតិ
ពង្រឹងសីលធម៌សង្គម និងសន្តិសុខសង្គម
ពង្រឹងសមភាពយេនឌ័រក្នុងស្រុក
អភិវឌ្ឍសហគមន៍ និងឲ្យមានការចូលរួមកិច្ចការសង្គម
ចូលរួមកែទម្រង់ប្រព័ន្ធតុលាការ  និងអនុវត្តច្បាប់
លើកកម្ពស់សិទ្ធិក្នុងការអប់រំសម្រាប់ទាំងអស់គ្នា
បង្កើតការជួបជុំអន្តរសាសនា តាមមូលដ្ឋាន
តាមដានស្ថានភាពនយោបាយ
បង្កើតក្លឹបកីឡា និងសិក្សាដល់យុវជន
បង្កើតទីផ្សារការងារក្នុងស្រុក (មានប្រាក់ឈ្នួលសមរម្យសម្រាប់ប្រជាពលរដ្ឋ)
សេរីភាពសារពត៌មាន និងសិទ្ធិទទួលបានសេវាព័ត៌មាន
គាំទ្រយុវជនក្នុងការចូលរួមអភិវឌ្ឍសហគមន៍
លើកកម្ពស់សិទ្ធិទទួលបានសេវាសាធារណៈ
អភិរក្សវប្បធម៌
ការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ
ពង្រឹងវិស័យសុខាភិបាល

# Final Statement

165 people attended a seminar "Research on Key Values to Build Cambodian Society in the 21st Century ". The participants were staff members and professors of St. Paul's Institute including 13 high school principals from Takeo province, along with them were the representatives of civil society, of the pastoral office and of the Bergamo University of Italy. Bishop Olivier Schmitthaeusler of the Apostolic Vicariate of Phnom Penh and the principal of the Institute coordinated the seminar.

The seminar took place from the 18th to the 20th May 2015 organised by St. Paul's Institute, in cooperation with the United Nations Educational, Scientific and Cultural Organization ( UNESCO ) and the Bergamo University.

All the participants, who attended the seminar, discovered that humans are the core of values in any decision-making process that lead to discover the benefits of respecting human rights, values and dignity in the spirit of responsibility and enthusiastic involvement with solidarity and fraternity.

In the context of contributing to the development by the Cambodian society and the Association of South-East Asian Nations whose members are Indonesia, Malaysia, Thailand, Singapore, Vietnam, Brunei, Laos, Cambodia, Myanmar, and the Philippines ( ASEAN ), the fundamental principles are as follows:

- Strengthen a public forum with participation by all;
- Promote the right to education for all;
- Enhance the capacity for creativity and skills;
- Organise structures and partnerships with neighboring countries;
- Formulate social media networks and good education policies.
- Strengthen physical infrastructures;
- Implement co-decentralization policies;
- Foster self-development;
- Urge parents to send their children to school;
- Initiate a sweeping change in the education system;
- Encourage inter-religious dialogue;
- Strengthen leadership in all sectors;
- Eliminate corruption at all levels;

- Strengthen the health system in the country
- Freedom of expression for the common good of all.
- Initiate social morality and security;
- Strengthen gender equality;
- Develop community and socially oriented programmes;
- Participate in the judicial system reforms and law enforcement;
- Follow political developments;
- Form sporting and study clubs for youth;
- Create jobs for the local market ( decent wages for citizens );
- Freedom of the press and access to information;
- Support youth in community development;
- Promote access to public services;
- Preserve cultures and traditions
- Apply laws equally without fear or favour.

## IV. សុន្ទរកថាក្នុងឱកាសបិទសិក្ខាសាលារបស់លោកអភិបាល អូលីវីយេ

នេះជាពេលដែលយើងបិទសិក្ខាសាលារយៈពេលបីថ្ងៃ អំពី"គុណតម្លៃសម្រាប់ការកសាងសង្គមកម្ពុជាក្នុងសតវត្សទី២១"។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមយ៉ាងសកម្មអស់ រយៈពេលបីថ្ងៃ ពីសំណាក់លោកសាស្ត្រាចារ្យ បុគ្គលិក លោកគ្រូ អ្នកគ្រូ នាយកសាលា និងនិស្សិតទាំងអស់ ព្រមទាំងបងប្អូនដែលអញ្ជើញមកពីភ្នំពេញ ពីអង្គការនានា និងពីការិយាល័យនានា...។

រយៈពេលបីថ្ងៃនេះ ទាំងនៅក្នុងអង្គប្រជុំដើម្បីស្តាប់វាគ្មិនណែនាំ ទាំងនៅក្នុងក្រុមការងារ បងប្អូនទាំងអស់គ្នាបានចូលរួមយ៉ាងសកម្ម។ ខ្ញុំមានកាដូពិសេសសម្រាប់ជូនអ្នកគ្រូStefaniaGandolfi និងសហការីរបស់គាត់មកពីប្រទេសអ៊ីតាលី ដែលបានបង្រៀន និងបានឧបត្ថម្ភកម្មវិធីរបស់យើងព្រមទាំងបានជួយលើកទឹកចិត្តយើងយ៉ាងច្រើនក្នុងរយៈពេលបីថ្ងៃនេះ។ខ្ញុំសូមអរគុណចំពោះលោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យនៃវិទ្យាស្ថានសន្តៈប៉ូល ដែលបានរៀបចំសិក្ខាសាលានេះ ដោយបានយកចិត្តទុកដាក់លើកទឹកចិត្តដល់និស្សិតដែលជួយណែនាំតាមក្រុមផ្សេងៗ ក្នុងរយៈពេលបីថ្ងៃនេះ។ សូមអរគុណ ក្រុមដែលបានណែនាំក្រុមការងារ និងក្រុមដែលបានជួយឲ្យយើងមានសុខមាលភាព គឺក្រុមចុងភៅ ក្រុមអនាម័យ ក្រុមនិស្សិតដែលណែនាំឲ្យសិក្ខាសាលារបស់យើងទទួលជោគជ័យ។

ខ្ញុំគិតថា លទ្ធផលនៃសិក្ខាសាលានេះ ជាឧទាហរណ៍មួយដាក់ស្តែងបង្ហាញថាយើងចេះសហការគ្នា។ គ្រប់សកម្មភាពដែលយើងធ្វើរយៈពេល ៣ថ្ងៃកន្លងមកនេះយើងបានខិតខំសហការគ្នាហើយការសហការនេះណែនាំឲ្យយើងទទួលជោគជ័យរួមគ្នា។ ដូចនេះវាជាមោទនភាពសម្រាប់យើងទាំងអស់គ្នានិងខ្ញុំគិតថារបៀបដែលយើងបានសហការគ្នារបៀបដែលយើងបានជួយគ្នាទៅវិញទៅមក ជារបៀបមួយបង្កើត "ផលប្រយោជន៍រួម" ។ នៅក្នុងសិក្ខាសាលានេះ យើងមានបទពិសោធន៍ដាក់ស្តែងអំពីផលប្រយោជន៍រួមជាអ្វី?។ ប្រធានបទថ្ងៃទី១ យើងបានចាក់គ្រឹះមូលដ្ឋាននៃសិក្ខាសាលាយើងគឺបុគ្គលជាស្នូលនិងជាកំពូលនៃអ្វីៗទាំងអស់។ចាប់ពីថ្ងៃចាប់ផ្តើមរហូតដល់ថ្ងៃបញ្ចប់យើងបានរកឃើញថា បុគ្គលជាស្នូលជាកំពូលដែលណែនាំការរិះគិតរបស់យើងគ្រប់ពេលវេលា។យើងបានរិះគិតអំពីតម្លៃថ្លៃថ្នូរ និងសិទ្ធិរបស់មនុស្សយើងបានខិតខំបើកចិត្តគំនិតរបស់យើងស្វែងយល់អំពីសាសនានានា និងយើងបានខិតខំសម្លឹងមើលពីការប្រឈមដែលយើងត្រូវតែជួបនៅសតវត្សទី២១សម្រាប់ប្រទេសកម្ពុជាយើង ក៏ដូចជាអាស៊ានទាំងមូល។

ដូច្នេះទាំងអស់នេះណែនាំឲ្យយើងទទួលបានផលប្រយោជន៍រួមគួរឲ្យកត់សម្គាល់ ដូចលោកគ្រូ គុលបញ្ញា បានលើកឡើងថា សហគមន៍អាស៊ានយើងគិតអំពីគម្រោងការនយោបាយ និងសេដ្ឋកិច្ច តែគ្មានអ្នកណាដែលគិតអំពីការកសាងចិត្តមនុស្ស និងអំពីសិទ្ធិមនុស្សទេ។ តែអ្វីដែលយើងបានខិតខំធ្វើ គឺជាថ្មមួយយ៉ាងតូចជាថ្មដែលមានតម្លៃដើម្បីឲ្យយើងទៅមុខបាន។ រួមជាមួយគ្នាយើងបានខិតខំស្វែងរកឲ្យឃើញ

សេចក្តីពិត និងស្វែងយល់ពីសេចក្តីពិតនោះ ហើយនេះក៏ជាគោលដៅនៃសាកលវិទ្យាល័យនីមួយៗដែរ។

ដូច្នេះ ខ្ញុំមានសំណូមពរសម្រាប់វិទ្យាស្ថានសន្តៈប៉ូលដូចតទៅ៖

- **ទីមួយ** ខ្ញុំសង្ឃឹមថា វិទ្យាស្ថាននឹងទៅជាកន្លែងមួយដើម្បីបើកចិត្តគំនិតឲ្យទូលំទូលាយ និងឲ្យយើងរៀនសូត្រអំពីរបៀបដែលយើងអាចទទួលមនុស្សដែលប្លែកពីយើង។ ពេលយើងនិយាយថាទទួលស្វាគមន៍មនុស្សដែលប្លែកពីគ្នានោះមានន័យថាយើងចង់បង្កើតសាកលវិទ្យាល័យមួយជាសង្គមតូចមួយដែលនិស្សិតទាំងអស់មានកន្លែងដើម្បីនៅ។យើងមិនគិតតែនិស្សិតដែលមានសមត្ថភាពតែយើងគិតពីនិស្សិតដែលគ្មានសមត្ថភាពដែរគឺគិតដល់និស្សិតទាំងអស់ដើម្បីឲ្យកន្លែងរបស់យើងទៅជាកន្លែងស្វាគមន៍គ្នាទៅវិញទៅមក។
- **ទីពីរ** ឲ្យវិទ្យាស្ថានសន្តៈប៉ូល ទៅជាកន្លែងមួយដែលណែនាំឲ្យយើងយល់អំពីវប្បធម៌នានាដែលមាននៅក្នុងពិភពលោកទាំងមូល។ លើសពីនេះទៀតឲ្យវិទ្យាស្ថានទៅជាកន្លែងមួយដែលយើងស្រាវជ្រាវយ៉ាងពិតប្រាកដ។វិទ្យាស្ថានយើងមានបណ្ណាល័យ មានអ៊ីនធើណេត និងមានឧបករណ៍ផ្សេងៗទៀតជាច្រើនដើម្បីជួយក្នុងការស្រាវជ្រាវរបស់យើងឲ្យយើងស្វែងយល់អំពីវប្បធម៌នានា។
- **ទីបី** ខ្ញុំសង្ឃឹមថាវិទ្យាស្ថានសន្តៈប៉ូលនឹងទៅជាកន្លែងមួយកែច្នៃគំនិត និងប្រឌិតនូវគំនិតថ្មីៗ។ ខ្ញុំសង្ឃឹមថាក្លិបទេពកោសល្យរបស់យើង នឹងជួយឲ្យវិទ្យាស្ថានយើងទៅជាកន្លែងមួយដែលមានគំនិតថ្មីៗ ដើម្បីអភិវឌ្ឍប្រទេសកម្ពុជា។
- **ទីបួន** ឲ្យវិទ្យាស្ថានទៅជាកន្លែងមួយ ដែលបញ្ចេញពន្លឺរស្មីខាងផ្លូវវិញ្ញាណ ជាកន្លែងមួយជួយឲ្យសាសនានីមួយៗយល់ចិត្តគ្នាថែមទៀត ជាកន្លែងមួយផ្តល់នូវកម្លាំងឲ្យយើងបន្តការសន្ទនាអន្តរសាសនាក្នុងចំណោមបងប្អូនជាពុទ្ធបរិស័ទ បងប្អូនជាគ្រីស្តបរិស័ទ និងបងប្អូនជាអ៊ីស្លាមបរិស័ទហើយក៏ឲ្យយើងអាចរកឃើញនូវប្រភពដើម្បីចិញ្ចឹមជីវិតខាងផ្លូវវិញ្ញាណរបស់យើងទាំងអស់គ្នាដែរ។ បើផ្លូវវិញ្ញាណរបស់មនុស្សយើងស្ថិតរីងស្ងួត នោះយើងមិនអាចធ្វើជាផ្កាមួយទងយ៉ាងស្រស់ស្អាតដើម្បីឲ្យពិភពលោករបស់យើងមានភាពស្រស់ស្អាតនោះបានឡើយ។
- **ទីប្រាំ** ឲ្យវិទ្យាស្ថានសន្តៈប៉ូលទៅជាកន្លែងមួយឲ្យនិស្សិតទាំងអស់គ្នាទទួលជោគជ័យទាំងនិស្សិតពូកែនិងនិស្សិតដែលមិនពូកែដែរ គឺឲ្យនិស្សិតទាំងអស់អាចបញ្ចេញអស់ពីសមត្ថភាពរបស់គេម្នាក់ៗក្នុងការសិក្សា។ សំខាន់និស្សិតដែលខ្សោយជាងគេឲ្យគាត់មានឱកាសបញ្ចេញសមត្ថភាពដោយអស់ពីសមត្ថភាពរបស់គាត់។ សូមឲ្យវិទ្យាស្ថានរបស់យើងទៅជាកន្លែងមួយដែលផ្តល់ជោគជ័យដល់និស្សិតទាំងអស់ក្នុងការសិក្សាក្នុងការកសាងជីវិតរបស់គេដោយឲ្យម្នាក់ៗមានឱកាសបញ្ចេញទេពកោសល្យ របស់គេដោយអស់ពីសមត្ថភាពរបស់គេ។

ហេតុនេះហើយ ប្រសិនបើយើងរួមគ្នា ទាំងបុគ្គលិក ទាំងសាស្រ្តាចារ្យ ទាំងនិស្សិត នោះយើងអាចបញ្ចេញអស់ពីសមត្ថភាពរបស់យើងដើម្បីថែរក្សាទស្សនៈរបស់យើងជាទស្សនៈរួមដែលណែនាំឲ្យម្នាក់ៗយកចិត្តទុកដាក់និងទទួលខុសត្រូវយ៉ាងខ្ពស់ដែលណែនាំឲ្យយើងអាចទទួលបានជោគជ័យ។ ទស្សនៈរួមរបស់យើងគឺស្វែងរកសេចក្តីពិតនៅក្នុងធម៌មេត្តាករុណា។ បើយើងថែរក្សាទស្សនៈរួមនេះបាននោះខ្ញុំគិតថាវិទ្យាស្ថានសន្តៈប៉ូលយើងនឹងទៅជាកន្លែងដ៏អស្ចារ្យសម្រាប់យុវជនយុវនារីឲ្យគេកសាងប្រទេសកម្ពុជាយ៉ាងល្អអស្ចារ្យ។

ខ្ញុំសូមអរគុណនិងសូមជូនពរ សូមតទៅមុខទៀតឲ្យយើងស្ថិតនៅក្នុងអំណរសប្បាយ នៅក្នុងសេចក្តីសុខសាន្តដោយថែរក្សាសេចក្តីពិតនិងការទទួលខុសត្រូវមួយយ៉ាងខ្ពស់ជានិច្ច។

Mercredi 20 mai 2015

Chers amis.

Notre séminaire sur les valeurs pour construire notre société du 21ème siècle, s'achève.

Grand merci à tous pour votre participation active.

Merci à madame Gandolfi et à Rita.

Merci à l'équipe enseignante de saint Paul.

Merci aux invités. Aux animateurs de workshops.

Merci à l'équipe de l'ombre qui a permis que nous mangions bien, que nous ayons électricité et confort.

La réalisation de ce séminaire est un bel exemple de collaboration où chacun a pu donner le meilleur de lui-même pour le succès de l'ensemble.

C'est une façon de travailler au bien commun.

Dès lundi, nous avons voulu dire combien la personne était centrale et devait être mise au cœur de toute notre réflexion.

Nous avons parlé de dignité humaine et des droits de l'homme.

Nous avons ouvert nos esprits et nos cœurs à la pensée des religions.

Nous avons essayé de lire les défis auxquels la société est confrontée.

Dans quelques instants, nous lirons les actes de ce colloque qui sont le ré sultat d'un travail collectif.

Nous avons essayé sincèrement de chercher la vérité.

C'est bien le but de l'université.

Je souhaite que notre université puisse devenir un pôle d'ouverture et d'éducation à la diversité. ( rencontre avec d'autres pays de l'ASEAN, échanges d'étudiants )

Je souhaite que notre université devienne un pôle culturel ouvert sur le monde. (Conférences, séminaires de recherche , bibliothèque, internet)

Je souhaite que notre université devienne un pôle d'innovation ( clubs agri

culture, informatique et d’autres à inventer)

Je souhaite que notre université devienne un pôle de rayonnement spirituel où chacun puisse venir comprendre la religion de l’autre et puiser des forces intérieures pour se construire.

Je souhaite que notre université devienne un pôle d’excellence où chacun est pris en compte pour se développer au maximum de ses capacités.

Nous y réussirons si, ensemble, équipe éducative et administrative avec tous les Etudiants, nous donnons le meilleur de nous mêmes dans cette vision commune qui nous rassemble et nous met fasse à nos responsabilités: vérité et charité !

De tout cœur, MERCI à tous !

+ Olivier Schmitthaeusler




# ឧបត្ថម្ភដោយ

ASSOCIAZIONE
VITTORINO
CHIZZOLINI
COOPERAZIONE INTERNAZIONALE- ONLUS

UNESCO
Organisation des Nations Unies pour l'éducation, la science et la culture

uniTwin
Chaire UNESCO en droits de l'homme et éthique de la coopération internationale

CATTEDRA UNESCO
Université de Bergame


ភូមិអង្គគីរ ឃុំតាមភេម ស្រុកត្រាំកក់ ខេត្តតាកែវ
032 639 00 03 / 032 639 00 02